ទស្សនាវដ្ដី លេខ ៦

# ពុទ្ធិកវិទ្យាល័យ

ង 129




ង 129 ង

R-6 10-7-56

# មាតិការឿង


. . . . . . វិចារណកថា ទំព័រទី ១

បណ្ឌិតសម-សុខុម . . . ពុទ្ធទស្សនៈ (ត) „ ៦

. . . . . . ដំណើរសាសនា „ ១០

មហា ជោន-ទិត . . . . ស្ថានការណ៍នៅសហភាពភូមា „ ១៤

. . . . . . សេចក្ដីរាយការណ៍អំពីប្រជុំនៃ
គណៈកម្មាធិការទីប្រឹក្សាពុទ្ធគយា „ ១៧

ភិក្ខុ អាំ-សួន (ហៅហម) . រចនាវិលាសវាក្យភាសាអង់គ្លេស „ ២១

លោក ប៉ាយ-ប៊ុក . . . . រឿងតុក្កតាធ្វើពីទធិជាតិ (ត) „ ២៤

លោកតែ-ជុន . . . . . ជ័យប្រាជ្ញ (ត) „ ២៨

លោកសួន-សារិន . . . . បុណ្ណកុមារ (តនិងចប់) „ ៣១


---

## ដំថ្លៃជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ ខែ | ១ ឆ្នាំ | ១ ក្បាល | ៦ ខែ | ១ ឆ្នាំ | ១ ក្បាល |
| ៥០៛០០ | ១០០៛០០ | ១០៛០០ | ៦០៛០០ | ១២០៛០០ | ១៣៛០០ |

## អ្នកទទួលឲ្យជាវ

សូមផ្ញើចំពោះទៅលោក ម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ

ADRESSE: Monsieur Mao-Mey Ministère de L'Intérieur P.Pen -

# វិចារណកថា

## ព្រះរាជជីវប្រវត្តិនៃសម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ

សម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ អតីតព្រះមហាក្សត្រ ព្រះអង្គទ្រង់ប្រសូត្រនៅថ្ងៃទី ៣១ តុលា ១៩២២ ។ ព្រះវររាជបិតានៃអង្គ គឺព្រះករុណាជាអម្ចាស់ជីវិតលើត្បូងព្រះបាទនរោត្តម សុរាម្រិត ព្រះមហាក្សត្រប្រទេសកម្ពុជាសព្វថ្ងៃនេះ ព្រះវររាជមាតាគឺសម្តេចព្រះមហាក្សត្រិយាណី ស៊ីសុវត្ថិកុសុមៈនារីរតន៍ ។ តាមព្រះរាជក្រសែនៃព្រះវររាជបិតានិងព្រះវររាជជននីនាថ សម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ ជាព្រះរាជទាយាទត្រោះតពីព្រះមហាក្សត្រខ្មែរដែលកសាងប្រាសាទនៅអង្គរមក ។

សម្តេចទ្រង់កំពុងតែសិក្សាបង្ហើយព្រះវិជ្ជានៅវិទ្យាល័យស៊ាស្លូ-ឡូបាត់ ស្រាប់តែនៅថ្ងៃទី ២៣ មេសា ១៩៤១ ព្រះអង្គបានត្រូវគេអញ្ជើញឲ្យយាងមកសោយរាជ្យ តពីព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទស៊ីសុវត្ថិមុនីវង្ស ជាព្រះរាជអយ្យកោរបស់ព្រះអង្គ ។ ព្រះអង្គទ្រង់ទទួលនូវព្រះរាជាភិសេកនៅថ្ងៃទី ២៨ តុលា ក្នុងឆ្នាំដដែល ។

នៅពេលចប់សង្គ្រាមលោកលើកទី ២ ព្រះបាទនរោត្តម សីហនុ បានទ្រង់ប្រទានច្បាប់រដ្ឋធម្មនុញ្ញខាងលទ្ធិប្រជាធិបតេយ្យនិងសេរីភាព ដល់ប្រជារាស្ត្ររបស់ព្រះអង្គ (ថ្ងៃទី ៦ ឧសភា ១៩៤៦) ។ ព្រះអង្គបានបំពេញព្រះរាជករណីយកិច្ចយ៉ាងលំបាក ប៉ុន្តែជាករណីយកិច្ចប្រកបដោយសេរីជោគជ័យដ៏ខ្ពង់ខ្ពស់ គឺបានទទួលពីប្រទេសបារាំង នូវឯករាជ្យពេញលេញជូនដល់ប្រទេសរបស់ព្រះអង្គ ដែលកាលពីពេលមុនជាប្រទេសនៅក្នុងអាណាព្យាបាលបារាំង ដោយឥតមានសម្រក់ឈាម ១ តក់នឹងមិនធ្វើឲ្យខូចមិត្តភាព

ពីបារាំងផង ។ ព្រះអង្គសម្រេចបានឯករាជ្យនេះ ក្រោយព្រះរាជពលិកម្មអស់រយៈពេល ៨ ឆ្នាំ គឺព្រះអង្គទ្រង់ទាមទារបន្តិចម្តងៗ ជាប់ជាប់ឥតមានបន្ធូរបន្ថយឡើយ ។

ប្រទេសបារាំងបានលះបង់កិច្ចការអាណាព្យាបាលរបស់ខ្លួន កាលពីថ្ងៃទី ៧ មករា ១៩៤៦ ហើយបានទទួលស្គាល់ឯករាជ្យប្រទេសកម្ពុជាទុកជាសមាគតរដ្ឋក្នុងសហភាពបារាំង កាលពីថ្ងៃទី ៨ វិច្ឆិកា ១៩៤៩ ។ ប៉ុន្តែប្រទេសបារាំងនៅអភិរក្សទុកនូវសមត្ថកិច្ចជាច្រើន ដែលនាំឲ្យមានសេចក្តីសង្ស័យពីបទឯករាជ្យដ៏ពិតប្រាកដ ។ ព្រះបាទនរោត្តម សីហនុ កាលដែលទ្រង់កាន់ដំណែងជានាយករដ្ឋមន្ត្រី (ថ្ងៃទី១៥ មិថុនា១៩៥២) ក៏បានទ្រង់ចាប់ផ្តើមជាមួយប្រទេសបារាំង នូវកិច្ចចរចាដ៏យ៉ាងរន្ធឹករន្ធារហៅថា «ព្រះរាជពលិកម្ម» ហើយក្រោយសម័យប្រកបដោយក្តីតានតឹងយ៉ាងខ្លាំង ទើបទ្រង់បានសម្រេចដល់នូវជោគជ័យបរិបូណ៌ គឺថានៅពេលបំណាច់ឆ្នាំ ១៩៥៣ ប្រទេសបារាំងបានប្រគល់ជូនដល់ព្រះរាជអាណាចក្រកម្ពុជា នូវអំណាចទាំងប៉ុន្មានដែលខ្លួនកាន់ទុកនោះ ។

កិច្ចព្រមព្រៀងឆឺណែវ (កក្កដា ១៩៥៤) ពង្រឹងឯករាជ្យខ្មែរ ព្រមទាំងបាននាំមកជូនប្រទេសវិញ នូវសន្តិភាពនិងសន្តិសុខ ។ ក្នុងរយៈកាលជាបន្ទោះ ពួកឥស្សរៈបានស្ងប់សាបសូន្យស្ទើរតែទាំងអស់ ដោយការសុំចុះចូលមេធំៗ នៃពួកខ្មាំងជាតិនិយមទាំងឡាយ ។

សម្តេចបានទ្រង់សន្យាឲ្យរាស្ត្ររបស់ព្រះអង្គជំនុំជំរះកាត់សេចក្តីរូបព្រះអង្គចុះ នៅអវសានកាលនៃព្រះរាជបេសកកម្ម ដើម្បីឯករាជ្យនេះ ។ ព្រះអង្គបានទ្រង់គោរពសេចក្តីសន្យារបស់ព្រះអង្គមែន បានជាមានធ្វើប្រជាមតិកាលពីថ្ងៃទី ៧ ខែកុម្ភៈ ១៩៥៥

ហើយព្រះអង្គបានទ្រង់ទទួលឆ្នោតចំនួន ៩២៥៨១២ យល់ព្រម ឯឆ្នោតជំទាស់មាន ១.៨៣៤ តែប៉ុណ្ណោះ ។

នៅកណ្ដាលសេរីជោគជ័យដ៏ឧត្ដមនេះ ព្រះបាទនរោត្តមសីហនុទ្រង់ដាក់រាជសម្បត្តិភ្លាម ( ៣ មីនា ១៩៥៥ ) ។ ក្នុងព្រះរាជសុន្ទរកថាដែលទ្រង់បានថ្លែងនៅឯក្រុងញូវ-ដេល្ហីនៅចំពោះមុខលោកស្រីនេប្រារដ្ឋមន្ត្រីទី ១ នៃប្រទេសឥណ្ឌា ព្រះអង្គបង្ហាញនូវហេតុទាំងឡាយនៃព្រះរាជកាយវិការដែលទ្រង់មិនបានប្រុងទុកនេះ ។ ព្រះអង្គទ្រង់មានព្រះបន្ទូលថា: ព្រះអង្គត្រូវបំពេញករណីយកិច្ចមួយទៀត គឺកសាងលទ្ធិប្រជាធិបតេយ្យដ៏បរិសុទ្ធ និងបំបាត់មិនឲ្យក្រុមអភិជនដ៏តូចមួយជិះជាន់រាស្ត្ររបស់ព្រះអង្គ ។ សម្ដេចទ្រង់មានព្រះរាជបន្ទូលថែមទៀតថា: ដែលព្រះអង្គទ្រង់ស្ថិតនៅក្នុងឋានៈជាព្រះមហាក្សត្រ ព្រះ ព្រះអង្គទ្រង់នៅជាប់តែមួយកន្លែងរកបំពេញកិច្ចការអ្វីៗបាន ។ ព្រះអង្គទ្រង់បញ្ចប់ព្រះរាជសុន្ទរកថាដោយមានព្រះបន្ទូលថា: ព្រះអង្គលះបង់រាជបល្ល័ង្កដើម្បីបំរើប្រជារាស្ត្រឲ្យបានសព្វគ្រប់គ្រាន់ហើ ។

ព្រះរាជករណីយកិច្ចជាប្រថមគឺប្រមូលផ្ដុំប្រជារាស្ត្រខ្មែរ ដើម្បីប្រយុទ្ធប្រឆាំងនឹងអយុត្តិធម៌ខាងសង្គម ប្រឆាំងនឹងការស៊ីសំណូក ហើយនឹងការកាន់អំណាចផ្ដាច់ការ ។ ព្រះអង្គបានទ្រង់ជួយបង្កើត « សង្គមរាស្ត្រនិយម » ដែលប្រមូលឲ្យមានសមាជិកប្រ-ហែល ៥០០.០០០ នាក់ ហើយបានសំឡេង ៨២ % ( ព្រមទាំងមានតំណាងរាស្ត្រទាំងអស់នៅរដ្ឋសភា ) នៅសម័យបោះឆ្នោតកាលពីថ្ងៃទី ១១ កញ្ញា ១៩៥៥ ។

កាលដែលទ្រង់ឡើងកាន់អំណាច កាលពីថ្ងៃទី ៣ តុលា ១៩៥៥ ជាមួយក្រុមមួយប្រកបដោយឥស្សរជននៅក្មេងៗ ប៉ុន្តែមានឥទ្ធិពល សម្ដេចព្រះនរោត្តមសីហនុ ឧបយុ-

វិញ ក្នុងរយៈពេលតែ ៣ ខែ ទ្រង់បានធ្វើឲ្យសម្រេចពិតប្រាកដ នូវកិច្ចការដ៏សម្បើមគឺ កែប្រែរដ្ឋធម្មនុញ្ញ បង្កើតឲ្យមានសមាជជាតិ សភាខេត្ត ដែលមានអំណាចយ៉ាងទូលំទូលាយ ផែនការពីរឆ្នាំសម្រាប់ប្រទេស ។ល។

កាលពីថ្ងៃទី ៣១ ធ្នូ ១៩៥៥ដទៃពីសមាជជាតិ សម្តេចបានត្រូវគេជ្រើសតាំងឯកឆន្ទថ្វាយឋានៈជាប្រធាននៃសង្គមរាស្ត្រនិយម ។

តាំងពីសម័យនោះមក សម្តេចមិនបានត្រួតត្រាប្រទេសកម្ពុជាទេ ព្រះអង្គគ្រាន់តែធ្វើជាអ្នកដឹកនាំខាងផ្លូវនយោបាយតែប៉ុណ្ណោះ ។ កិច្ចអន្តរាគមរបស់ព្រះអង្គក្នុងសមាជផ្សេងៗ មានសភាពដ៏ល្បីល្បាញ ។ គឺដោយអាស្រ័យព្រះរាជបញ្ញារបស់ព្រះអង្គនេះហើយ បានជាអព្យាក្រិតភាពប្រទេសខ្មែរ (តុល្យភាពយ៉ាងមាំរវាងខាងលិចនឹងខាងកើត) ត្រឡប់ទៅជាមូលដ្ឋានដ៏រឹងប៉ឹងឥតកម្រើក នៃអាកប្បកិរិយារបស់រដ្ឋាភិបាលទាំងឡាយបន្ទាប់ៗមក ដោយរួបរួមជាមួយប្រជារាស្ត្រទាំងមូល ។ ព្រះអង្គបានបញ្ចូលប្រទេសកម្ពុជានៅក្នុងអង្គការសហប្រជាជាតិ ។ ព្រះអង្គបានទ្រង់ធ្វើព្រះរាជដំណើរទៅក្រុងតូក្យូ ក្រុងម៉ានីល ក្រុងប៉េកាំង ដែលក្នុងទីនោះៗ មិត្តភាពក្នុងសម័យបុរាណដែលបាត់បង់យូរណាស់មក ហើយត្រូវព្រះអង្គធ្វើឲ្យកើតមានឡើងវិញ ព្រមទាំងព្រះអង្គបានទ្រង់ធ្វើឲ្យមានការប្រស្រ័យទាក់ទងខាងសេដ្ឋកិច្ចប្រកបដោយប្រយោជន៍ធំ ។ ឥឡូវនេះសម្តេចព្រះអង្គទ្រង់ស្តេចយាងទៅកាន់ក្រុង ម៉ាឌ្រិត (អេស្ប៉ាញ) ក្រុងវ៉ារសូវី (ប៉ូឡូញ) ប្រាគ (ចេកូស្លូវ៉ាគី) នឹងក្រុងម៉ូស្គូ (សហភាពសូវៀត) ជាព្រះរាជដំណាងនៃព្រះករុណាជាម្ចាស់ជីវិតលើត្បូងនិងប្រជាជាតិ ។ ដោយសារតែព្រះអង្គ ទើបប្រទេសកម្ពុជាចាប់ពីពេលនេះទៅបានស្ថិតនៅលើឆាកអន្តរជាតិបាន

ជាអតីតសិស្សនៃសាលាទ័ពសេះនិងខាងទ័ពរថក្រោះជា «សូមូរ» សម្តេចទ្រង់ជាឧត្តមសេនីយឯកនៃកងយោធពលខេមរភូមិន្ទ ដែលព្រះអង្គទ្រង់ធ្វើជាមេបញ្ជាជាច្រើនលើកនាសមរភូមិ កាលទ្រង់នៅជាព្រះមហាក្សត្រនិងជាអធិមេបញ្ជាការ ។

ព្រះអង្គបានទ្រង់ប្រយុទ្ធក្នុងទិសខាងជើងតនឹងពួកឧទ្ទាម នៅដំណាច់ឆ្នាំ ១៩៥៣ ប្រឆាំងនឹងកងកំឡាំងបរទេសជាសត្រូវក្បែរបាត់ដំបង (ប្រតិបត្តិការសាមគ្គី) កាលពីក្ន ខែធ្នូ ១៩៥៣ ព្រមទាំងក្នុងតំបន់ស្ទឹងត្រែងនិងក្រចេះ ។

សម្តេចទ្រង់មានព្រះចរិតជាអ្នកអត់ឱនទោស មានសេចក្តីគួរសម មានព្រះហឫទ័យរីករាយ មានព្រះរាជហឫទ័យល្អចំពោះអ្នកក្រីក្រ ព្រមទាំងមានព្រះរាជហឫទ័យស្មោះត្រង់ជាយ៉ាងក្រៃលែង ។ ដោយអាស្រ័យគុណសម្បត្តិនៃព្រះរាជហឫទ័យយ៉ាងដូច្នេះហើយ ទើបព្រះអង្គទ្រង់ជាទីស្នេហានៃប្រជារាស្ត្ររបស់ព្រះអង្គ និងជាទីរាប់អាននៃបរទេសជាច្រើន ។

ម្យ៉ាងទៀត គេតែងដឹងថាសម្តេចជាអ្នកនិពន្ធបទភ្លេងដ៏ឆើត ហើយមានទំនុកភ្លេងរបស់ទ្រង់ជាច្រើនបានត្រូវលេងឯបរទេសផង មិនតែប៉ុណ្ណោះសម្តេចទ្រង់ជាអ្នកជិះសេះយ៉ាងប៉ិនប្រសប់ ព្រមទាំងប្រព្រឹត្តជីវភាពជាសាមញ្ញ ។



## ពុទ្ធទស្សនៈ (ត)

២– ទុក្ខសមុទយអរិយសច្ចៈ ព្រះពុទ្ធជាម្ចាស់ទ្រង់បរិយាយថាៈ តណ្ហា គឺសេចក្ដីប្រាថ្នា របស់ណាដែលធ្វើឲ្យមានការកើតទៀតប្រឡូកប្រឡំដោយអំណាចនៃសេចក្ដីរីករាយក្នុងអារម្មណ៍នោះ ៗ ។ តណ្ហានោះដូចម្ដេចខ្លះ? គឺ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។

អធិប្បាយថាៈ តណ្ហា គឺសេចក្ដីចង់បានឬសេចក្ដីរេចតាកយ៉ាងស្រពន់ , ខ្វល់ខ្វាយក្នុងផ្លូវដែលឲ្យបានសមតាមបំណង ៖

– កាមតណ្ហា គឺសេចក្ដីប្រាថ្នាក្នុងរូបឬរបស់ ឬសេចក្ដីសុខសម្បូណ៌នឹងសេចក្ដីពេញចិត្តរបស់ខ្លួន ដែលនៅមិនទាន់បាន នឹងសេចក្ដីវង្វេងវិលវល់ក្នុងរបស់នោះ ៗ ដែល

ខ្លួនបានហើយ ។

– ភវតណ្ហា គឺសេចក្ដីប្រាថ្នាក្នុងភពដែលខ្លួនកើត ដោយអំណាចសេចក្ដីអាល័យ នឹងសេចក្ដីប្រាថ្នាចង់កើតក្នុងភពតទៅ ; សេចក្ដីប្រាថ្នាជានេះជានោះ ក៏សង្គ្រោះចូលក្នុងប្រភេទនេះដែរ ។

– វិភវតណ្ហា សេចក្ដីប្រាថ្នានូវភពដទៃ គឺមិនចង់នៅក្នុងភពដែលកើត (ចង់ចុតិចាកភពនោះៗ) ដោយសេចក្ដីនឿយណាយ ; នឹងសេចក្ដីប្រាថ្នាចង់ឲ្យរលត់សូន្យក្នុងភពនោះមិនចង់កើតតទៅទៀត ; សេចក្ដីមិនប្រាថ្នានេះជានោះក៏សង្គ្រោះចូលក្នុងប្រភេទនេះដែរ ។

៣– ទុក្ខនិរោធអរិយសច្ច ព្រះពុទ្ធជាម្ចាស់ទ្រង់បរិយាយថា: សេចក្ដីរលត់ដោយមិនសេសសល់នៃតណ្ហា គឺការបណ្ដាលចុះនូវតណ្ហា ការដាក់ចុះនូវតណ្ហា ការលះលែងនូវតណ្ហា ។

អធិប្បាយថា: កាលបើដឹងហើយថា តណ្ហាជាហេតុនៃសេចក្ដីទុក្ខគប្បីលះបង់នូវតណ្ហាចេញឲ្យអស់រលីង ទើបសេចក្ដីទុក្ខរលត់ទៅបាន ។

៤– ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ព្រះពុទ្ធបរមគ្រូជាម្ចាស់ទ្រង់បរិយាយថា: សេចក្ដីបដិបត្តិដើម្បីសេចក្ដីរលត់ទុក្ខនោះដោយផ្លូវមានអង្គ ៨ ជាគ្រឿងឲ្យរួចចាកកិលេសដែលជាសត្រូវ ៖

១– សម្មាទិដ្ឋិ, ២– សម្មាសង្កប្ប,

៣– សម្មាវាចា, ៤– សម្មាកម្មន្ត,

៥– សម្មាអាជីវ, ៦– សម្មាវាយាម,

៧– សម្មាសតិ ,   ៨– សម្មាសមាធិ ។

ផ្លូវមានអង្គ ៨ ដែលពោលក្នុងទីនេះហៅតាមភាសាមគធថា "អដ្ឋង្គិកមគ្គ" (សរសេរក្លាយជាអក្សរខ្មែរថា: "អដ្ឋ័ង្គិកមគ្គ") ឬតាមសព្ទភាសាសំស្ក្រឹតថា "អស្ដាង្គិកមគ្គ" (សរសេរក្លាយជាអក្សរភាសាខ្មែរថា: "អស្ដាង្គិកមគ្រ") មានអធិប្បាយពន្យល់ចេញទៅទៀតដូចតទៅនេះ

១– សម្មាទិដ្ឋិ ប្រែថា ការយល់ឃើញត្រូវដោយត្រង់ បានដល់សេចក្ដីយល់ឃើញត្រូវតាមគន្លងធម៌គ្រប់ប្រការ ។ តាមអដ្ឋកថាថា: បានដល់ការឃើញផលល្អនិងផលអាក្រក់ តែងកើតឡើងព្រោះតែកម្ម គឺយើងធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ។ មានជនពួកខ្លះយល់ឃើញថា "ការធ្វើល្អ. អាក្រក់នោះ នៅវេលាដែលទីងឲ្យផល ក៏ព្រោះតែមានបុគ្គលឃើញ, បើធ្វើអំពើអាក្រក់ហើយបិទបាំងមិនឲ្យបុគ្គលដទៃដឹងក៏ឈ្មោះថាអាចបានផលល្អឬក៏មិនទទួលផលអាក្រក់សូម្បីបន្តិចបន្តួចឡើយ" ម្ល៉ោះហើយក៏នាំគ្នាប្រព្រឹត្តកន្លង សូម្បីមនុស្សដែលធ្លាប់ប្រព្រឹត្តល្អ អំពីដើមមកក៏ដោយ កាលបើគេឃោសនាយ៉ាងនេះ ក៏ប្រព្រឹត្តតាមបុគ្គលដែលឃោសនានោះ តែបុគ្គលដែលមានអំណាចបុណ្យវាសនាមិនដឹងមិនឮមិនយល់តាម ឬមិនពេញចិត្តក៏អាចត្រិះរិះឲ្យជំនាញក្នុងខ្លួនបាន ។ បុគ្គលដែលយល់ឃើញដូចខាងលើនេះ រាប់ថា:ជាអ្នកមានសេចក្ដីយល់ខុសដោយពិត ។

២– សម្មាសង្កប្ប ប្រែថាដំរិះត្រូវគឺមិនត្រិះរិះស្វែងរកសេចក្ដីសុខសម្រាន្តនិងសេចក្ដីរីករាយក្នុងផ្លូវខុស , មិនត្រិះរិះប្រកបដោយការចង់ព្យាបាទ ។

៣– សម្មាវាចា ប្រែថាវាចាត្រូវបានដល់វចីសុចរិត ៤ ប្រការគឺ មិននិយាយពាក្យកុហក ១ , មិននិយាយពាក្យញុះញង់សឹកសៀត ១ , មិននិយាយពាក្យចាក់ដោត ១ , មិន

និយាយពាក្យរោយរាយឥតប្រយោជន៍១, ។ បណ្ដាការនិយាយមិនត្រូវតាមសេចក្ដីពិតគ្រប់ស្ថាននេះ ចាត់ថាជា « មុសាវាទ » ។ ការនិយាយញុះញង់បុគ្គលទាំងសងខាងឬបុគ្គលច្រើនគ្នាឲ្យបែកសាមគ្គីគ្នា ឲ្យទាស់ខ្វែងខុសចិត្តគ្នា ឲ្យទាស់ទែងដល់គ្នានឹងគ្នា ចាត់ថាជា « បិសុណាវាទ » ។ ការនិយាយអុជអាលគេដោយការស្បថស្បែរហូតដល់ការដុតដាលចាក់រុក និងនិន្ទា ចាត់ថាជា « ផរុសវាទ » ។ ការនិយាយរោយរាយមិនមានសារៈចាត់ថាជា « សម្ផប្បលាបៈ » ។

៤– សម្មាកម្មន្ត ប្រែថាការងារត្រូវ បានដល់កាយសុចរិត ៣ ប្រការគឺ មិនសម្លាប់សត្វ ១ , មិនលួចទ្រព្យគេ ១ , មិនប្រព្រឹត្តខុសក្នុងកាម ១ , ។

រឿងមិនសម្លាប់សត្វ ជាបញ្ហាធ្លាប់មានមកតាំងពីសម័យពុទ្ធកាល , គឺតែងមានអ្នកខ្លះសួរថា: បុះបើមិនសម្លាប់សត្វបានអ្វីធ្វើជាអាហារ ; នៅមានជនមួយពួកទៀតសឹងមានសេចក្ដីប្រាថ្នាឲ្យដឹងជាក់ច្បាស់ ហើយសំដែងសេចក្ដីយល់ឃើញថា បើពិនិត្យពិច័យក្នុង១ហាមមិនឲ្យសម្លាប់សត្វនេះគួរតែហាមមិនឲ្យបរិភោគសាច់សត្វជាដាច់ខាត ។ ទេវទត្តដែលបែកចេញចាកគណពុទ្ធសាវក ក៏ព្រោះតែមានទិដ្ឋិយល់យ៉ាងនេះឯង ។

ខ្ញុំយល់យ៉ាងជាក់ស្ដែង ក្នុងរឿងហាមមិនឲ្យសម្លាប់សត្វនេះ ; ជនភាគច្រើននៅមិនទាន់ចូលចិត្តស៊ប់ថា: ព្រះពុទ្ធទ្រង់មានព្រះបំណងដូចម្ដេចនោះនៅឡើយ , ចំណែកឯដែលថា: ព្រះអង្គទ្រង់មានមេត្តាដល់សត្វទាំងឡាយទើបព្រះអង្គទ្រង់ហាមដូច្នោះ ខ្ញុំចូលចិត្តថា: ព្រះអង្គទ្រង់បំណងដល់ការសម្លាប់សត្វ ដើម្បីបូជាយញ្ញសែនព្រេនដល់ទេវតាតាមទំនៀមរបស់ព្រាហ្មណ៍នោះច្រើនជាងការសម្លាប់សត្វដើម្បីជាភក្សាហារដល់មនុស្ស ; ការសម្លាប់សត្វសែនទេវតា ធ្វើឲ្យសត្វដែលធ្វើគុណប្រយោជន៍ដល់មនុស្សត្រូវទទួលអន្តរាយជីវិតជាច្រើន ដោយប្រាថ្នាផលល្អរោយប្រការទាំងពួង ។ (នៅមានត)

# ដំណឹងសាសនា

(គ)

ខទី៥– នៅថ្ងៃទីបំផុតបុណ្យ វេលាថ្ងៃរសៀលមានធ្វើពិធីនិមន្តព្រះសង្ឃបិណ្ឌបាត ៗ (រឿងបិណ្ឌបាតថ្ងៃរសៀលនេះ ប្រាកដជាមានអស់លោកខ្លះឆ្ងល់ថា ម្ដេចបានជាព្រះសង្ឃទៅបិណ្ឌបាតថ្ងៃរសៀល ៗ រឿងនេះពិតដូចឆ្ងល់មែន (តែព្រះសង្ឃដែលនិមន្តទៅនោះមិនមានត្រូវការទទួលយកទេយ្យវត្ថុនោះ ៗ ដោយផ្ទាល់ដៃខ្លួនឯងទេ គ្រាន់តែនិមន្តដើរបង្ហាញអង្គប៉ុណ្ណោះ, ឯតែសព្វយ៉ាង ស្រេចហើយតែកប្បិយការកៈដែលកាន់ល្អីកញ្ជើរដើរតាមក្រោយឯណោះ) ៗ ការធ្វើបុណ្យដាក់បាត្រនេះសោតក៏ផ្សេងដោយឡែកទៅទៀត មិនមែនដាក់បាយសម្លដូចធម្មតានោះទេ គឺឧបាសក-សិកាចំណុះជើងវត្តពាណិជ្ជករដែលមានសទ្ធាជ្រះថ្លាចែកគ្នាជាក្រុមជាពួកដាក់ទេយ្យវត្ថុផ្សេងៗមានស្បង់ចីពរ, ផ្ដិលចានប៉ាន់តែងតែស្ករ, អង្ករត្រីងៀតក្ដួយ បាត្រនិងគ្រឿងសិក្ខុបករណ៍ផ្សេង ៗ ជាដើម ៗ ក្រុមខ្លះមានធ្វើសលាកឲ្យព្រះសង្ឃចាប់ ដោយទេយ្យវត្ថុមានមុខផ្សេងគ្នា ៗ ការដាក់ទេយ្យវត្ថុនេះ ក្នុងក្រុមមួយ ៗ ត្រូវដាក់ឲ្យគ្រប់ចំនួនភិក្ខុសង្ឃដែលនិមន្តមក ៗ នៅទីបុណ្យខ្លះមាននិមន្តភិក្ខុសង្ឃដល់ទៅ២០០អង្គឬ១.០០០អង្គឬក៏៦០-៧០អង្គ តាមបុណ្យធំ-តូច ៗ លុះដល់កាលវេលាហើយ ពួកពុទ្ធសាសនិកទាំងនោះ ក៏សំអិតសំអាងខ្លួនយ៉ាងរៀបរយបុះបែប ហើយនាំយកនូវទេយ្យវត្ថុនោះ ៗ ដែលគេកំណត់ទុក ៗ នៅទីនោះគណៈកម្មការក៏រៀបចំដំកល់ទេយ្យវត្ថុវិចិត្រ ដែល

តម្រៀបជាជួរ ៗ សង្កាត់ផ្លូវជាក្រុម-សង្កាត់ តាំងពីលានព្រះចេតិយរហូតមកបំរុងប្រគេនព្រះសង្ឃ ៗ ចំណែកឯព្រះសង្ឃវិញក្នុងមួយអង្គ ៗ ត្រូវឲ្យមានកប្បិយការកៈម្នាក់ ឬពីរនាក់ កាន់កូនកញ្ជេរឬកញ្ជើរដើរតាមក្រោយ ដើម្បីទទួលយកនូវទេយ្យវត្ថុនោះ ៗ ។ រួមទេយ្យទានទាំងអស់ទៅ បើគិតជាសាច់ប្រាក់វិញ ក្នុងមួយអង្គ ៗ ត្រូវបានប្រហែល១០០ឬ១៥០ក្បាល ។ ពិធីបុណ្យបិណ្ឌបាតនេះ បើតាមសព្ទភូមាថា «ស្វូងវ័ងសេង» ប្រែថា «បិណ្ឌបាតវត្ថុស្រស់,» គឺរបស់ទាំងអស់សុទ្ធតែជារបស់ស្រស់នៅមិនទាន់ចំអិន ។ (តែបើតាមសំនួរខ្មែរ ប្រែជាស្រៅបន្តិចហើយ) ។

ខទី៦– ក្នុងថ្ងៃដដែលនោះ (ថ្ងៃទីបំផុតបុណ្យ) នាកាលចប់ពិធីដាក់បាត្រហើយ គណៈកម្មការក៏ផ្តើមធ្វើពិធីផ្សៀងឆ្នោត មានឃោសនាប្រកាសដល់ជនទូទៅដែលមានសន្លឹកឆ្នោតឲ្យមកជួបជុំគ្នា ។ ពិធីបើកការផ្សៀងឆ្នោតនេះ គេជ្រើសរើសរកកុមារីដែលមានអាយុ១៤-១៥ឆ្នាំ ៥ឬ៦នាក់ តម្រូវទឹងលេខឆ្នោតដែលមានប៉ុន្មាន ៗ ខ្ទង់នោះ ឲ្យប្រដាប់គ្រឿងអលង្ការយ៉ាងហ៊ឺហាគួរឲ្យចាប់ចិត្ត ដែលតាមពិនិត្យមើលទៅសំលៀកបំពាក់នៃកុមារីទាំងនោះ ទោះសំពត់ស្ទៀកក្តី អាវក្តី ស្បែកជើងក្តី សុទ្ធតែជារបស់ដែលកើតមានឡើងក្នុងប្រទេសភូមា ដោយស្នាដៃជនជាតិភូមាពិត ៗ មិនឃើញមានកែងចោតឬអាវរ៉ប ដែលក្លាយចេញមកពីសីលធម៌របស់អឺរ៉ុបឡើយ, ដើម្បីឲ្យមករៃប្រអប់បញ្ចូលលេខឆ្នោត ។ ប្រអប់នោះ មានសណ្ឋានមូលទ្រវែង, មានដៃរវៃដូចជារហ័តមានចោះប្រហោងប្រហែល២-៣សង្ទីម៉ែត្រ ល្មមតែដាក់ឈើដុំលេខទៅខាងក្នុងបាននឹងគួរដល់ការវង្វៀតចេញមកក្រៅបាននៃដុំលេខនោះផង ។ ក្នុងខណៈដែលដល់ពេលហើយគណៈកម្មការក៏កំណត់សម្លេងតាមខ្សែសូសនសព្ទថា មួយ-ពីរ-បី ដើម្បីឲ្យ

កុមារីទាំងនោះរវៃប្រអប់ព្រម ៗ គ្នា ក្នុងកាលដែលដុំលេខខាងក្នុងចេញមកតាមលំដាប់ខ្ទង់ហើយ គេក៏តម្រៀបដុំលេខនោះតាមលំដាប់តាំងពីគុទី១ ដល់គុទី៥-៦ព្រោះប្រអប់វៃនោះ ៗ មានរបៀបជាលំដាប់លំដោយ ៗ គឺកុមារម្នាក់កាន់ប្រអប់វៃមួយ ៗ ហើយក៏ប្រកាសនូវចំនួនលេខនោះមានឧឃោសនស័ព្ទម្ដងជាពីរដង ៗ ការធ្វើបែបនេះដរាបដល់អស់ចំនួនមុខវត្ថុ ៗ បណ្ដាជនទាំងនោះ ជនរូបណាដែលបានលទ្ធផលរង្វាន់ទី១ តាមទំនៀមភូមា ជនរូបនោះ ត្រូវតែនិមន្តព្រះសង្ឃវត្តនោះ៤-៥អង្គដែលមានលោកគ្រូចៅអធិការជាប្រមុខ នឹងនិមន្តព្រះពុទ្ធបដិមាករមួយអង្គក្នុងវត្តនោះ ទៅកាន់ផ្ទះរបស់ខ្លួនដើម្បីប្រគេនភត្តមួយពេល នៅថ្ងៃណាមួយ ៗ ឯការដែលមកដង្ហែរយកព្រះពុទ្ធរូបឬព្រះសង្ឃទៅកាន់ផ្ទះនោះ ក៏មានចាត់ក្បួនដែរ គឺមានភ្លេងតូរ្យតន្ត្រីមួយវង់នឹងជនប្រុស-ស្រីមកដង្ហែរពីវត្តយកទៅ ៗ លុះព្រះសង្ឃធ្វើភត្តរួច ក៏និមន្តព្រះពុទ្ធរូបត្រឡប់មកកាន់អារាមវិញ មានចាត់ក្បួនដូចដែលកាលហែរយកទៅដែរ ៗ

ពិធីបុណ្យនេះ តាមការសាកសួរនឹងពិនិត្យទៅ ឃើញថាក្នុងមួយលើក ៗ សល់បច្ច័យ (ប្រាក់) សម្រាប់ជួសជុលព្រះចេតិយឬពុទ្ធាគារចំនួន៤០០០ ឬ ៦០០០ក្យាត, ព្រោះមុននឹងបោះសន្លឹកឆ្នោតលក់នោះ គេបានគិតគូបូកប៉ាន់ដាត់នាយ-អាយដឹងចំនួនហើយស្រេច ទើបគេលៃបោះសន្លឹកឆ្នោត ៗ

អធិប្បាយមកនេះ មិនបានជាពិស្ដារណាប់ណាទេ ដោយកាត់ប្រួញសេចក្ដីណា ៗ ដែលមិនជាការចាំបាច់, សូមមេត្តាត្រិះរិះដោយខ្លួនឯងផងទៀតចុះ ៗ

## ទី២– ពិធីបុណ្យប្រហាំឆ្នាំ ក្នុងប្រទេសសៀម

បុណ្យនេះ ក៏មានមូលហេតុតែមួយដូចគ្នានឹងបុណ្យនៅប្រទេសភូមាដែរ គឺដើម្បីប្រមូលបច្ច័យបំរុងជួសជុលនឹងសាងទីសេនាសនៈសម្រាប់ព្រះសង្ឃគង់សិក្សារៀនសូត្រ ៗ

តាមភាសាសៀមថា "ត៉ាំនប្រចាំពី" ប្រែថា "បុណ្យប្រចាំឆ្នាំ" ។ ពិធីបុណ្យនេះសង្ឃឹមថា គង់មានអស់លោកជាច្រើនរូបបានដឹងជ្រាបដោយជាក់លាក់ ។ ម៉្លោះហើយសូមអធិប្បាយប្លូត ៗ ចាប់យកតែគ្រោងហេតុធំ ៗ មកតែម្តង ។ នៅប្រទេសសៀមរបៀបធ្វើពិធីបុណ្យនេះ មានការប្លែកពីប្រទេសកម្ពុជាច្រើន ។ មានបោះសន្ទឹកកម្មវិធីផ្សាយជាមុនដូចគ្នាដែរ, តែក្នុងវេលាមុនថ្ងៃចូលបុណ្យ ចំនួនមួយសប្តាហ៍ ឬក៏លើសបន្តិចបន្តួច ពពួកជនអ្នកលក់ដូរម្ហូបម្ហា, គ្រឿងប្រដាប់ផ្សេង ៗ នឹងពួកអ្នកលក់ប្រដាប់កីឡា ឬអ្នកដែលមានប្រដាប់កីឡាជួលឲ្យអ្នកដែលទៅមើលបុណ្យនោះ ៗ ដះលេងប្តូរធំល្បែងផ្សេង ៗ ទៀត នាំគ្នាសស្រោកសស្រាំចូលទៅរកគណៈកម្មការបុណ្យដើម្បីទិញក្រឡាដីធ្វើជាបង្ហាលក់ដូរទំនិញផ្សេង ៗ ។ ឯការវាស់ក្រឡាដីវត្តលក់នោះស្រេចហើយតែគណៈកម្មការគេជំនុំគ្នាថាត្រូវលក់មួយម៉ែត្រក្រឡាថ្លៃប៉ុន្មាន ៗ ។ ចំពោះល្ខោនយីកេនឹងរូបភាពយន្ត គណៈកម្មការបានទៅជួលមោះដោយខ្លួនឯង ឲ្យមកលេងក្នុងរោងតាលដែលបានកំណត់ទុក ហើយកសាងរោងត្រឹមត្រូវសម្រាប់ល្ខោន-កុននោះ ៗ ដើម្បីលក់បណ្ណយកប្រាក់ដាក់ទុកសម្រាប់វត្តដែលសល់ពីតម្លៃថ្លៃល្ខោន-កុននោះ ៗ ។ ជួនកាល មានពុទ្ធមាមកជនខ្លះ មានសទ្ធាជ្រះថ្លានាំយករូបភាពយន្តរបស់ខ្លួនទៅបញ្ចាំងចាប់គង់កុសលក្នុងពិធីបុណ្យនោះ ។ នៅក្នុងព្រះវិហារឬពេង ៗ ប្រាសាទដែលមានព្រះពុទ្ធបដិមាករធំ-តូច ដំកល់ទុកជាទីសក្ការបូជានោះ គេក៏រៀបប្រដាប់តាក់តែងៈលេចក្បាច់ដោយភ្លើងអគ្គិសនីដែលជាទីគួរពិតពិលរមិលមើលយ៉ាងក្រៃលែង ព្រោះនៅទីនោះប្រជាជនដែលទៅមើលបុណ្យទាំងប៉ុន្មាន ត្រូវតែទិញធូប-ទៀន, ក៏ផ្កានឹងមាសសន្លឹកដែលគណៈកម្មការបានចាត់ដាក់លក់តាមតុ ៗ ដើម្បីយកទៅដុតឬបិទបូជាចំពោះព្រះពុទ្ធបដិមាករ ។ (នៅមានត)

# ស្ថានការណ៍នៅសហភាពភូមា (ត)

នៅទីបូជនីយដ្ឋាននីមួយៗ ទោះបីនៅកណ្ដាលទីក្រុងក្ដី, ក្នុងស្រុកនិគមជនបទក្ដី គេតែងឃើញមនុស្សម្នាមហាជនសញ្ចរទៅមកអឹងអាប់កុះករពុំដែលដាច់ ហាក់ដូចជាបបួលគ្នាទៅបុណ្យកឋិន បុណ្យផ្កា ឬក៏ពិធីបុណ្យអ្វីផ្សេងៗដែរ ។ ម្យ៉ាងទៀត ទីកន្លែងណាជាទីប្រជុំកុះករដោយមហាជន គេបួលចិត្តស្ថាបនាបូជនីយដ្ឋានផ្សេងៗត្រង់កន្លែងនោះ ព្រោះគេយល់ថា « គ្មានស្ថានអ្វីវិសេសវិសាលជាងបូជនីយដ្ឋាននានាទេ បូជនីយដ្ឋាននេះហើយជាតម្លៃថ្លៃថ្នូររបស់ប្រទេសជាតិជាកិត្តិយស ដ៏ឧត្តមរបស់ប្រទេស ឬក៏ជាសិរីសួស្ដីជោគជ័យមង្គលយ៉ាងឆ្នើម នឹងជាដួងថៃរបស់ប្រជាជនផង ។

៣- ភាសាជាតិ, អក្សរសាស្ត្រជាតិ ៖ ពលរដ្ឋសហភាពភូមាពេញចិត្តក្នុងការពោលនិយាយថ្លែងការណ៍ភាសាជាតិជាត្រីមុខ គឺនិយមនិយាយភាសាជាតិ និយមប្រើភាសាជាតិជាជាងភាសាជាតិដទៃ រាប់អានភាសាជាតិគេជាងភាសាជាតិដទៃ មានភាសាអង់គ្លេសជាដើម ។ នៅគ្រប់ក្រសួងនានាក្នុងការរដ្ឋមន្ត្រី នឹងមន្ត្រីតូច-ធំ និយមប្រើភាសាជាតិណាស់ទាំងអក្សរសាស្ត្រ ក៏និយមប្រើជាផ្លូវការណ៍គ្រប់ក្រសួងទាំងអស់ ទោះបីផ្លូវការណ៍នោះទាក់ទងដោយសំបុត្រ ឬបង្កាន់ដៃក៏ដូចគ្នាដែរ, វៀរលែងតែការងារនោះជាប់ទាក់ទងដល់សញ្ជាតិដទៃ មានជាតិអង់គ្លេសជាដើម ដោយខានប្រើពុំបាន ហើយមិនជាការចាំបាច់ប៉ុន្មានឡើយ ។ ឯភាសានិងអក្សរសាស្ត្រ ដែលជាការចាំបាច់ជាដាច់ខាតនោះគឺភាសាជាតិភូមា អក្សរសាស្ត្រជាតិភូមាប៉ុណ្ណោះឯង ។ ១ ទៀតគេបានបង្កើតអង្គលីលេខ មានបែបផែនជាអក្សរសាស្ត្រជាតិគេប្រើបានគ្រប់គ្រាន់ទូទៅទាំងប្រទេស ។ ទោះបីអង្គលីលេខនោះៗ ល្អក្ដី មធ្យមក្ដី ឬក៏ខ្វះពាក្យជាផ្លូវការណ៍ពុំគ្រប់គ្រាន់ក្ដី ក៏គេនិយមប្រើជាឯកសម្គីដែរ ដោយគេពុំប្រើអាការៈគន់បន្ទាប

បន្ថោកភាសាជាតិអក្សរសាស្ត្រជាតិគេឡើយ ។

ម្យ៉ាងទៀត ប្រជាជនទាំងអស់ ទោះជាបុរសក្តី ស្រីក្តី ច្រើនចេះភាសាជាតិស្ទើរតែទាំងអស់ ។ នៅមណ្ឌលឬតម្បន់មួយ ៗ ពេលដែលគេសញ្ចរទៅមកតាមវិថីតូច-ធំ, កាលបើងាកក្អែកក្រឡេកទោះទៅកាន់គេហស្ថានមួយ ៗ តែងឃើញមនុស្សប្រុសស្រីចាស់ក្មេងកម្លោះក្រមុំកាន់ទស្សនាវដ្តី ឬសារពត៌មានមើលអានពិនិត្យកិច្ចការផ្សេង ៗ ស្ទើរតែគ្រប់ផ្ទះ ។ ប្រជាជនភូមាទាំងអស់ដែលថាមិនចេះអក្សរសាស្ត្រប្រចាំជាតិគេនោះមានតិចគ្នាណាស់ ។ ពិតមែនតែប្រទេសនេះបានឯករាជ្យអស់រយៈកាលដ៏ខ្លីកន្លងមក ៨ ឆ្នាំប៉ុណ្ណោះ តែរដ្ឋាភិបាលព្រមទាំងពលរដ្ឋគេខំខ្នះខ្នែងប្រឹងប្រែងយកចិត្តទុកដាក់កសាងប្រទេសជាតិយ៉ាងម៉ឺងម៉ាត់មិនប្រទាំងដល់គ្នាឡើយ ។ គឺថាភ្នាក់ងារមន្ត្រីតូច-ធំរូបណាកាន់តំណែងមានមុខការនឹងនាទីកាន់កាប់ក្រសួងណា មន្ត្រីរូបនោះ ៗ គប្បីប្រឹងប្រែងយ៉ាងអស់អាចក្លាហាន ដើម្បីចាត់ចែងរៀបចំមុខការប្រចាំក្រសួងនោះ ៗ ឲ្យបានចំរើនល្អណាស់តែម្យ៉ាង មិនមើលបំណាំគ្នា មិនទំទៀនដល់គ្នាមិនប្រចាំគ្នាឡើយ គឺថាគេគិតបែបណាឲ្យតែចំរើនដោយគេដាក់គោលការៈថា ត្រូវតែនាំគ្នាផ្តល់ហិតប្រយោជន៍ជាសាធារណ៍ឲ្យដល់ពលរដ្ឋដល់ប្រទេសជាតិជាប្រមុខ ដោយខំប្រាយបែបណាឲ្យចំរើនទៅមុខមិនឲ្យថយក្រោយទេ បើជាស្ថានការណ៍នោះតឹងរឹងណាស់គ្រាន់តែឲ្យនឹងថ្កល់នៅ ហើយស្រាវទៅមុខប៉ុណ្ណោះ ។ ឯភ្នាក់ងារមន្ត្រីអ្នកកាន់ការក្នុងមុខក្រសួងនីមួយ ៗ ពុំសូវដែលឮល្បីថាអ្នកនោះលក់ខ្លួន លក់កេរ្តិ៍ឈ្មោះ បង់មារយាទ ចំពោះក្រសួងដែលខ្លួនកាន់កាប់ឡើយដោយគេយល់ថា មិនមែនធ្វើការគ្រាន់តែកេរ្តិ៍ឈ្មោះ ឬក៏គ្រាន់តែឲ្យគេថាខ្លួនជាមន្ត្រីធំ មិនមែនគ្រាន់តែបានប្រាក់ខែប៉ុណ្ណោះឡើយ ។ បើកិច្ចការនោះ ៗ

មិនចំរើនថ្នាក់ទៅក្នុងសេចក្ដីវិនាសក៏ដោយធម្មតា មិនមែនព្រោះការធ្វេសប្រហែស ឬធ្វើដោយខ្ជីខ្ជានោះឡើយ ។ ម្យ៉ាងទៀត ឯការសិក្សាភាសាជាតិក្ដី ភាសាបរទេសក្ដី ក៏គេប្រឹងសិក្សាទាំងស្រីទាំងប្រុសទាំងចាស់ទាំងក្មេង ដោយពុំបានគិតដល់ជំនន់វ័យផងឡើយ ។ នៅគ្រឹះស្ថានសិក្សាអាមេរិកាំងប្រចាំប្រទេសភូមា ក្នុង ១ យប់ ១ ថ្ងៃឃើញតែមហាជននាំគ្នាទៅសិក្សាភាសាអង់គ្លេសឥតអាក់ ទោះបីប្រជាជនខ្លះៗ អាយុរវាង ៤០ ឬ ៥០ ឆ្នាំហើយ ក៏នៅតែបន្តការសិក្សាដែរ, បុរសស្ត្រីខ្លះៗ ពេលថ្ងៃទៅធ្វើការ ពេលយប់ទៅសិក្សាគឺគេយល់ថាអាយុនៅមានដរាបណា ត្រូវប្រឹងធ្វើការព្យាយាមសិក្សាចំណេះវិជ្ជាដរាបនោះដោយពុំមានការខ្មាសអៀនព្រោះការប្រឹងរក ប្រឹងសង្វាតខំខ្នះខ្នែងឥតសំចៃកំឡាំងសោះឡើយ ។

៤– អំពីមុខរបរគ្រប់យ៉ាង ៖ ប្រជាជនភូមា មានការរវៀសរវៃក្រវើនក្រតើន ចំពោះមុខរបរគ្រប់យ៉ាងណាស់ដូចជារបរកសិកម្មក្ដី ពាណិជ្ជកម្មក្ដី ឧស្សាហកម្មក្ដី ក៏គេប្រឹងប្រែងយកចិត្តទុកដាក់ធ្វើការឥតសំចៃកំលាំងឡើយ ទាំងមិនសូវខ្ជិលច្រអូស ឬធ្វើការដោយខ្ជីខ្ជានោះឡើយ ។ ម្យ៉ាងទៀត ចំពោះបន្លែបង្ការបញ្ញារដំណាំអ្វីទាំងពួងដូចជាដូង ចេក អំពៅ ស្វា ទឹងស្ពៃ សាឡាត់ ខាត់ណា ជីរ ម្ទេះខ្ទឹម ស្លឹកគ្រៃ អំពៅ ត្រឡាច ត្រសក់ជាដើម គេឃើញមានដាំស្ទើរតែគ្រប់គេហស្ថាននៅដោយស្រុកខេត្ត ពុំសូវទិញដូរទេ ។ ចំណុចចិត្តនៃប្រជាជនទាំងនោះច្រើនចូលចិត្តប្រកបការងារខាងដំនួញ ប្រសប់ប៉ុនប៉ៅខាងលក់ដូរប្រហែលគ្នានឹងជាតិចិនដែរ ។

( នៅមានត )

# សេចក្ដីរាយការណ៍អំពីប្រជុំនៃគណៈកម្មាធិការទីប្រឹក្សា

## ពុទ្ធគយា ថ្ងៃទី១៩មិនា ១៩៥៦

លោកបណ្ឌិតរាជគ្រឹស្ណាន, អនុប្រធានាធិបតីនៃប្រទេសឥណ្ឌា បានអញ្ជើញមកកាន់ទីប្រជុំនៅវេលាម៉ោង១០និង៤៥នាទី ។ ក្រោយដែលបានជួបជុំគួរសម, បំពាក់ភួងផ្កាជូនអ្នកតំណាងគ្រប់ប្រទេសហើយ, លោកអនុប្រធានាធិបតីបានថ្លែងសាររលិកបើកសម័យប្រជុំនៃសន្និសីទ ។ បន្ទាប់មកលោក ស. ក. មូគ័រជី បានអានសេចក្ដីរាយការណ៍នៃគណៈកម្មាធិការចាត់ចែងទីស្ថានពុទ្ធគយា ។ គោលសំខាន់ៗនៃសេចក្ដីរាយការណ៍នោះ មានដូចតទៅនេះ៖



(នេះលទ្ធិអបេលក៍) ឧបាសិការពីររូបកំពុងចាប់ចង្ហាន់ប្រគេនលោកគ្រូ

បន្ទាប់អំពីការរអាក់រអួលបើយឺតយូរជាច្រើនលើកច្រើនគ្រា ដោយមានសេចក្ដីលំបាកតាមផ្លូវច្បាប់, នៅទីបំផុត ពុទ្ធគយាក៏បានមកស្ថិតនៅកន្ដាប់ដៃនៃគណៈកម្មាធិការចាត់ចែងការ កាលពីថ្ងៃពេញបូណ៌មីនៃខែពិសាខ គ.ស.១៩៥៣

គណៈកម្មាធិការនោះ មានសមាជិកដូចតទៅនេះ៖

១– លោកស៊ីរី អ. ន. សិង្ហ ប្រធានស្ដីទី, គយា,

២– លោកស៊ីរី ព្រជ កិស្ហោរ ប្រាសាទសិង្ហៈ សមាជិកសភា,

៣– លោកស៊ីទេវប្រិយ វលិសិង្ហ: អគ្គលេខាធិការនៃមហាពោធិសមាគមប្រទេសឥណ្ឌា;

៤– លោកស៊ីជ័នគេន-ភិក្ខុអគ្គលេខាធិការពុទ្ធិកសមាគមប្រទេសអស្សម;

៥– ភិក្ខុ ជគ្ទិស្ហកស្សប ចាងហ្វាងវិជ្ជាស្ថានបាលិ, នាលន្ទា;

៦– លោកស៊ីក្រិស្ណា មោសិនប្បារយ៍សិង្ហ, សមាជិកសភានីតិបញ្ញត្តិ;

៧– លោកស៊ីរ.ល.នន្ទកិអ៊ូល្យ៉ារ, ចៅក្រមគយា;

៨– លោកស៊ី មហាន្ត ហរិហ័រគិរិ, មហាន្តនៃឥស្សរាកមនៅពុទ្ធគយា;

៩– បណ្ឌិតអរ្ទិនបារូ, អគ្គលេខាធិការនៃពុទ្ធិសមាគមបង្គ័ល, កលេកត្តា ។

គណៈកម្មាធិការនេះ ត្រូវជ្រើសតាំងសម្រាប់រយៈកាលបីឆ្នាំ មានអ្នកកាន់ព្រះពុទ្ធសាសនាបួនរូបនឹងអ្នកកាន់សាសនាហិណ្ឌូប្រាំរូប, លោកស៊ីមហាន្តហរិហ័រគិរិជាប្រធាន។ លោកស៊ីរ.ល.នន្ទអ៊ូល្យ៉ារ បានទទួលអនិច្ចកម្មទៅកាលពីគ.ស. ១៩៥៥ ហើយលោកស៊ីត.ទ.ឃោសៈត្រូវបានតែងតាំងជាជំនួសឡើង ។

ហិរញ្ញវត្ថុដែលបានចូលមកគណៈកម្មាធិការជាប្រក្រតីនោះមានតែការបូជា នឹងអំណោយដោយសទ្ធានៃបូជនិយេសក៍ នឹងអ្នកទស្សនាដូចមានចំនួនខាងក្រោមនេះ៖

ពីថ្ងៃទី១-៦-៥៣ ដល់ថ្ងៃទី ៣១-៥-៥៤ចំនួនប្រាក់៦.៥៣៩រូបីយ៍៨/៩ពីថ្ងៃទី១-៦-៥៤ ដល់ថ្ងៃទី៣១.៣-៥៥-ចំនួនប្រាក់ ៦.៧០៥រូបីយ៍ /០/៣ ពីថ្ងៃទី១-៤-៥៥.។ ២៩-២-៥៦ ចំនួនប្រាក់៧.៨៤៣ រូបីយ៍/៧/ ០

គណៈកម្មាធិការបានទំនុកបម្រុងចំពោះក្រុមអ្នកថែទាំដូចខាងក្រោមនេះគឺ៖

ក, កម្មន្តនាយកមួយរូបដែលស្ថិតនៅពុទ្ធគយា (ជាអ្នកកាន់ព្រះពុទ្ធសាសនា);

ខ– ភិក្ខុពីររូប (នៅក្នុងបន្ទុកមហាពោធិសមាគមនៃប្រទេសឥណ្ឌា)៖

គ, អ្នកយាមមួយរូប;

ឃ– ទ្វារបាលពីររូប;

ការចំណាយទំនុកបម្រុងក្រុមនេះអស់ចំនួន២.២៦២រូពិយ៍ក្នុងមួយឆ្នាំ ៗ ការចំណាយរួមទាំងអស់នៃគណៈកម្មាធិការមានដូចតទៅនេះ៖

ពីថ្ងៃទី ១ ៦-៥៣ដល់ថ្ងៃទី៣១-៥-៥៤អស់ចំនួន៦.២១៨រូពីយ៍/១២/៦

" ១-៦-៥៤ " ៣១-៣-៥៥ " ៦-៦៦៨ " /១១/៩

" ១-៤-៥៥ " ២៩-២-៥៦ " ៦-២៣៧ " /៣/៣

ក្នុងគ.ស.១៩៥៣ រដ្ឋាភិបាលពិហារបានឲ្យគណៈកម្មាធិការខ្ចីប្រាក់ចំនួន៥.០០០ រូពីយ៍, ប៉ុន្តែក្នុងពេលថ្មី ៗ នេះ រដ្ឋាភិបាលពិហារមិនទទួលយកសំណងវិញទេ ដោយទុកប្រាក់នេះ ជាជំនួយក្នុងការសង់ទីសំណាក់ការនៃគណៈកម្មាធិការ ។

ង-ខ-នាយករដ្ឋមន្ត្រីនៃប្រទេសភូមា បានផ្ញើអំណោយដល់គណៈកម្មាធិការចំនួន



(នេះលទ្ធិអចេលក៍) បរិស័ទតាមហែលោកគ្រូទៅកាន់ទីនិមន្ត



(នេះលទ្ធិអបេលក៍) លោកគ្រូកំពុងសំដែងធម៌ដល់បរិស័ទ ទាំងស្រី ទាំងប្រុស

១០.០០០រូបិយ៍, ហើយបញ្ជាក់ថា ដល់ថ្ងៃពេញបូណ៌មីខែពិសាខមុខនេះនឹងធ្វើអំណោយ ១០.០០០រូបិយថែមទៀតសម្រាប់៤ឆ្នាំតទៅអនាគត ។ លោកស្រីប.មុនីសិទ្ធ:(ម្ដាយភិក្ខុអនុរុទ្ធ) ឧបាសិកាជាតិលង្កា, បានចំណាយទ្រព្យចំនួន៤.០០០រូបិយជាតម្លៃការដាក់ភ្លើងអគ្គិសនីបំភ្លឺព្រះមហាចេតិយ៍ពុទ្ធគយា, ហើយសម្ដេចព្រះឧបយុវរាជនរោត្តម-សីហនុ ប្រទេសកម្ពុជា ក្នុងពេលដែលទ្រង់បានស្ដេចមកទស្សនាធ្វើគារវកិច្ចចំពោះពុទ្ធស្ថានទ្រង់បានព្រះរាជទាន៥០០រូបិយ ដល់គណៈកម្មាធិការ ។ កាលពីថ្ងៃទី២៩កុម្ភៈ១៩៥៦គណៈកម្មាធិការបានជម្រះបញ្ជីដោយបូករួមទឹកប្រាក់ទាំងនេះ, ឃើញនៅសល់ចំនួន ១៦.៤៦៧ រូបិយ ៥០ ។

ដោយសមាជិកខ្លះ នៅឆ្ងាយដាច់ស្រយាលពេក ហើយគណៈកម្មាធិការមានធនធានស្ដួចស្ដើងផងនោះ ទើបមិនសូវមានការប្រជុំញឹកញាប់ឡើយ បានត្រឹមតែ៦គ្រាប៉ុណ្ណោះគឺក្នុងលើកទី ១ កាលពីថ្ងៃទី ២៩-៦-៥៣; លើកទី៣- កាលពីថ្ងៃទី ២៨-២៩ ធ្នូ ១៩៥៤ ។ (នៅមានត)

**IV- To get along well with;**

(To live or work harmoniously with)

1- Mr. Smith GETS ALONG WELL WITH all his employees.

2- Mr. and Mrs. Jones do not GET ALONG WELL; they quarrel (ខ្វ-រ៉ែល) constantly.

**V- To get along;**

( to go; to start. )

Well, it's time for me to GET ALONG.

**VI- Every so often=Every now and then;**

( Occasionally )

1- EVERY SO OFTEN he and 9 go to a ball game to-gether.

2- EVERY NOW AND THEN we go to movies (មូ៉-វីស៍)

**VII- To set in;**

( To commence )

The rainy season has SET IN.

**VIII- To fall through;**

( To remain in complete )

រស់នៅឬធ្វើការដោយរួបរួមគ្នា=សាមគ្គីគ្នាធ្វើការ– ចិញ្ចឹមជីវិត ;

លោកស្ម៊ិតធ្វើការដោយរួបរួមគ្នាជាមួយកូនឈ្នួលគាត់ទាំងអស់គ្នា ។

លោកនិងលោកស្រីជូន មិនសូវសាមគ្គីគ្នាទេ, គាត់ឈ្លោះគ្នាញយៗ ។

ទៅ; បន្តដំណើរ;

អា! ដល់ពេលត្រូវខ្ញុំបន្តដំណើរហើយ។

ម្ដងៗ; ម្ដងមួយកាល;

គាត់និងខ្ញុំ ទៅមើលល្បែងទាត់បាល់ជាមួយគ្នាម្ដងៗ ។

យើងទៅមើលកុនម្ដងមួយកាល ។

ចូលមកដល់; ចាប់ផ្ដើម;

រដូវភ្លៀងបានចូលមកដល់ហើយ ។

នៅមិនសម្រេច; នៅមេម៉ាយ;

ដោយការខ្វះប្រាក់ទុន, ផែនការក៏នៅមេម៉ាយ (ពុំស្រច)

បរកិនបរជាន់ ដោយចក្រយាន

ម៉េចក៏វាមិនបរឡាន ដោយប្រុងប្រយ័ត្ន

Through lack of funds, the scheme (ស្គីម) fell through.

**IX- To run over;**

( To strike or pass over with a moving vehicle.)

1- why doesn't he drive more carefully? He almost RUN OVER that child.

2- The man was RUN OVER by a train and killed.

**X- Above all;**

( mainly; especially )

1- ABOVE ALL, don't mention this to Henry.

2- The boy does well in all his subjects, but ABOVE ALL in mathematic.

ឡើង? វាបឡើនរឹសជាន់ក្មេងនោះ ។

បុរសនោះ ត្រូវរទេះភ្លើងកិនស្លាប់ទៅហើយ ។

ដោយសំខាន់បំផុត; ដោយចំពោះ; ជាពិសេស;

ដោយសំខាន់បំផុត, សូមកុំនិយាយរឿងនេះប្រាប់ហេនរី ។

កុមារនោះធ្វើបានល្អក្នុងវិជ្ជារបស់វាទាំងអស់; ប៉ុន្តែជាពិសេសក្នុងគណិតសាស្ត្រ ។

## JOKE

There was a man. in London, Bill Basher by name. He once went into a hotel for lunch. He TOOK OFF his over-coat. He knew well the kind of people who went to that hotel, so

## រឿងកំប្លែង

នៅក្រុងឡុនដ៍ន មានបុរសម្នាក់ឈ្មោះប៊ិល-បេស្ស៊ែរ ។ ពេលមួយនោះគាត់បានទៅកាន់សណ្ឋាគារមួយដើម្បីអាហារថ្ងៃ ។ គាត់ដោះអាវក្រុកគាត់ចេញ ។ គាត់ស្គាល់

he took a piece of paper and wrote on it: « This over-coat BELONGS TO Bill Basher, the famous fighter. He WILL BE BACK within ten minutes». Sud he put this on the coat and went into the dining-room. When he came back, the over-coat wasn't there; but on the paper someone had written, «Over - csat was taken by a famous runner. He WON'T BE BACK AT ALL».

ច្បាស់នូវជនគ្រប់បែប ដែលតែងទៅកាន់សណ្ឋាគារនោះ, ព្រោះហេតុនោះគាត់ចាប់យកក្រដាស១សន្លឹក ហើយសរសេរថា «អាវក្រុតនេះជារបស់ប៊ិល-បេស្សឺ ជាអ្នកកាប់ចាក់យ៉ាងឆ្នើម; វានឹងត្រឡប់មកវិញក្នុងរវាង១០មីនុត» គាត់ដាក់ (ក្រដាសដែលសរសេរហើយ) នេះលើអាវ ហើយចូលទៅកាន់បន្ទប់បរិភោគអាហារ ។ កាលគាត់ត្រឡប់មកវិញ ពុំឃើញអាវនៅកន្លែង (ដែលគាត់ទុក)នោះ; ប៉ុន្តែនៅក្រដាស (ដែលគាត់សរសេរ)នោះ មានគេសរសេរថា «អ្នករត់ដើងលឿនឆ្នើមម្នាក់បានយកអាវក្រុតទៅហើយ, វានឹងមិនត្រឡប់មកវិញសោះឡើយ ។

ចូរសង្កេតពាក្យរបៀបវិលាស ដែលដាក់ជាអក្សរធំ ៗ ។

(នៅមានត)

# រឿងតុក្កតាផ្ញើពីទធិជាតិ (ត)

ចំណែកខាងព្រះនាងទុក្ខពនីទ្រង់ស្ដេចទៅកាន់កំពង់ទឹក, ឯស្វា, យករូបិយមាសរត់បាសារ (bazar) [១]ស្វានោះបានជួលកម្មករដប់ប្រាំមួយនាក់ថ្លៃដប់ប្រាំមួយ មូហ៊ួរ (mohours) ទិញចំបើងដប់ប្រាំមួយរទេះហើយនឹងពីងពង់មួយពាន់ប្រាំមួយរយដើមៗ ក្នុងមួយរំពេច, កម្មករទាំងដប់ប្រាំមួយនាក់, ដោយស្វាជួយផង, បាននាំរទេះផ្ទុកចំបើងដប់ប្រាំមួយ នឹងពីងពង់មួយពាន់ប្រាំមួយរយដើមយកមករៀបចំខ្ទមព្រះនាងទុក្ខពនីជាថ្មី ។

រួចស្វានោះបានក្រាលផ្ទាល់ដីនូវសំពត់កន្ទះថ្មីមួយគុ (បីរ:) ថ្មីពីរ ។ បន្តិចទៀតពួកពិសេសទាំងដប់ប្រាំមួយនាក់ មកដល់ពីព្រះបរមរាជវាំង, បានយកព្រះក្រយា" របស់ព្រះនាង ។ ស្វាបានថ្លែងសេចក្ដីអំណរចំពោះពួកពិសេសនោះហើយបានឲ្យកម្រៃទៅពួកពិសេសម្នាក់ៗ ដប់ប្រាំមួយរូបិយមាស... ។

ព្រះនាងទុក្ខពនីដល់ទ្រង់ស្រង់ព្រះគង្គាហើយ, ទ្រង់វិលត្រឡប់មកកាន់គេហដ្ឋានវិញ...តែ...ព្រះនាងទ្រង់ទតឃើញអ្វី? ឬជានិមិត? ឬព្រះនាងទ្រង់ច្រឡំផ្លូវ? ព្រះនាងទ្រង់ទតឃើញគេហដ្ឋានមួយថ្មីមានដំបូលល្អ, ប្រក់ស្បូវថ្មី!...ៗ ហើយនៅលើដី?... ព្រះនាងទ្រង់ទតទៅឃើញសំពត់កន្ទះមួយថ្មី... ហើយនៅលើស្នួរ? មានសំពត់សារីមួយថ្មីដែរ!

ព្រះរាជនីទ្រង់មានបន្ទូលសួរទៅស្វាថា:

—« ស្វា, មាតាបានចាកចេញគេហដ្ឋានទ្រុឌទ្រោមហើយ ដល់ត្រឡប់មកវិញ,

---

១– បាសារ (bazar): សង្កាត់ក្នុងក្រុងដែលមានផ្ទះលក់ទំនិញ ។ តាមន័យទូបកប្រែ, ពាក្យនេះទៅជាពាក្យខ្មែរ " ផ្សារ ,, ។

មាតាក៏ស្រាប់តែចូលក្នុងគេហដ្ឋានថ្មី... ម្ដេចក៏ដូចនេះ, នាង„? ។

ស្វាក្រាបទូលព្រះនាងវិញថា:

"ឱព្រះមាតា, ព្រះករុណាព្រះរាជទានរូបិយមាស (មហ៊ុរ mohours) មកទូលបង្គំៗ បានដួសដុលធ្វើគេហដ្ឋាននេះឲ្យទៅជាថ្មី ហើយទូលបង្គំបានទិញសំពត់កន្ទះទីង (បីរ: piras) ។ ឥឡូវនេះ, ព្រះមាតាទ្រង់សោយព្រះក្រយាហារ (បាយ) ដ៏ល្អដែលដាក់លើភាជន៍មាស ហើយទឹកដោះគោក្នុងកែវមាស ។

ព្រះរាជនីទ្រង់គង់ហើយទ្រង់ចាប់សោយដំបូង ។ យូរណាស់មកហើយ, ព្រះនាងទ្រង់មិនដែលបានសោយព្រះក្រយាហារ, នឹងសុវណ្ណភាជន៍ឬដោសព្រះទន្តនឹងគ្រាសរចនាដោយដងមាសឡើយ!... ។ តែព្រះក្រយាហារដែលមានឱជារសប្លែកជាងគេ ហើយដាក់ទៅលើរតនវត្ថុដ៏ប្រសើរមិនអាចធ្វើឲ្យព្រះនាងទុកចិត្តឡើយ, ព្រះនាងទ្រង់នៅតែសង្ស័យមិនចេះអស់មិនចេះហើយ ទ្រង់មានបន្ទូលដោយព្រះអង្គឯងថា? ឥឡូវនេះ ព្រះមហាក្សត្រទ្រង់ព្រះរាជទានម្ហូបអាហារឆ្ងាញ់ពីសារដាក់នៅលើសុវណ្ណភាជន៍; ស្អែក, ទ្រង់បញ្ជូនអញទៅចម្ការដែលគេកប់សព (ថូបដ្ឋាន ឬ សរនដ្ឋាន), ក្រោយដែលទ្រង់គ្រាសបង្គាប់ឲ្យគេកាត់ក្បាលអញ" ។

ហើយព្រះនាងទ្រង់គង់នៅស្ងប់ស្ងៀម, មិនទុកចិត្តព្រះអង្គក្នុងកិច្ចដែលនឹងមានជាអនាគត... ហើយព្រះទ័យស្អាក់ស្ទើរនឹងបារម្ភយ៉ាងនេះ ក៏ចេះតែបន្តពេលទៅមុខទៀត មួយខែ, ពីរខែ, បីខែ... ។

x
x x

## ព្រះនាងទុក្ខរានីត្រឡប់វិលមកគង់ព្រះបរមរាជវាំងវិញ

គេហដ្ឋានថ្មីនៃព្រះនាងទុក្ខរានី ទៅជាបាក់បែកបន្តិចម្ដងៗ; ដំបូលទ្រុឌទ្រោម,

មានបន្ទរជាច្រើន, ព្រះពាយបក់បោកយកស្បូវខ្លះ, ហើយទឹកភ្លៀងក៏ហូរទម្លាយដំបូល គេហដ្ឋានលេចស្រោចទទឹកដល់ផែនដី... ។

ស្វាគិតហើយក៏ចូលទៅក្រាបទូលព្រះមហាក្សត្រ

ព្រះមហាក្សត្រទ្រង់ទតហើយមានព្រះបន្ទូលសួរស្វាថា: «តើមានការណ៍អ្វីទៀត, ស្វា ?»

ស្វាក្រាបទូលព្រះមហាក្សត្រថា:

«មហារាជ ព្រះបរមកត ព្រះអង្គអើយ
ទូលធ្ងន់ធ្ងើយ គួរភ័យណាស់ បង្គំទូល
គួរឲ្យខ្លាច(១) គំនិតខ្វី មុខពន្រ្ទូល
ចិត្តមិនបូល ខ្ញុំនញាប់ញ័រ ញាក់សូមទោស ។

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលទៅស្វាវិញថា: ឯងពោលមកចុះកុំឲ្យខ្លាចអ្វី ? ហើយស្វាក៏ក្រាបបង្គំទូលទៅទៀតថា:

ទូលបង្គំ សូមអភ័យ ទោសព្រះអង្គ
ប្រោសស្រោចស្រង់ ទើបបានស្រាល ពីទុក្ខា
ព្រះនាងទុក្ខ មុនជាប់ខែ អស់ដីកា
ព្រួយកាយា លំបាកគ្រប់ គួរអាណិត ! ។
វាយោបក់ បោកខ្លាំងក្រៃ ក្រាបបង្គំ
ក្សត្រជាធំ សូមមេត្តា ស្មោះស្និទ្ធពិត
ទុក្ករានី ផ្ទុំមិនបាន រង់រនិត

១– រូបមន្តបូរាណនេះគេតែងពោលខាងភាសាវិគ្គលីហើយមានគ្រប់រឿងព្រេងទាំងអស់ ។

សូមរាជរិទ្ធ ជួយរំរែក ឲ្យបានស្រួល ។

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលទៅកាន់ស្វាថា:

"—ម្តេចក៏ដូចនោះ? នុស្វា, ប្រញាប់ប្រាប់យើងឲ្យបានជ្រាបអស់អាថ៌សេចក្តី!

ហើយស្វាក៏ក្រាបបង្គំទូលព្រះមហាក្សត្រជាបទថា: "នៅកន្លែងខ្ទមនាងចាស់ទ្រុតទ្រោមរាង ខ្វល់ប្រមូលមកបែកបានបង្អួចស្ងួមពក ដំបូលហែកបូកស្បូវបុកពោកពាក់ ។

រស់នៅលំបាក គ្មានក្តួយប្រាសចាស ការពារមិនស្អែក

រងាអស់អង្គ ព្រះពាយរុកចាក់ មានស្ទែស្ងួមដាក់

នុសក្រាក់នៅតិច ។ រងារពន់ពេក សូមអតិរេក

ទ្រង់ប្រកបកិច្ច ឲ្យនាងបានស្រួល សូមទ្រង់កំភ្លេច

ជួយស្រោចស្រង់ស្រេច សូមស្តេចមេត្តា ។

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលថា! នុពិតដូច្នោះឬ? បេះមានរឿងបែបនេះកើត? យើងត្រូវតែដឹងមុននេះ... ។

នុស្វា, ប្រញាប់. ឯងទៅអញ្ជើញមាតាឯង, ព្រះទុក្កភាទីមក; យើងនឹងជួសជុលបន្ទប់មួយនៅកន្លែងព្រះបរមរាជវាំងសម្រាប់ឲ្យព្រះនាងគង់នៅពីថ្ងៃនេះតទៅ ។

ស្វាក្រាបទូលព្រះមហាក្សត្រថា.

"—សូមទ្រង់ព្រះមេត្តាប្រោស, ទូលបង្គំមិនហ៊ានអញ្ជើញព្រះមាតាទូលបង្គំឲ្យមកនៅទីនេះទេខ្លាចក្រែងព្រះរាជនីក្មេងបំពុលព្រះមាតាទូលបង្គំ" ។ (នៅមានត)

# ជ័យប្រាជ្ញ (ត)

អ្នកចាំទ្វារ ចុះឯងឃើញនៅត្រង់ណា ?

កុមារជ័យ — ហ្ន៎ះ ! ខ្ញុំឃើញនៅត្រង់ច្បារមួយដើមឯណោះ ៗ

អ្នកចាំទ្វារ — បើដូច្នេះចូរអាឯងទៅយកមកមើល ៗ

កុមារជ័យ — ទេខ្ញុំខ្លាចណាស់មិនហ៊ានទៅយកទេ ៗ

អ្នកចាំទ្វារនោះគិតថានេះច្បាស់ជាពន្លឺពេជ្រ បើដូច្នេះត្រូវតែឲ្យអាជ័យវានៅទីនេះ អញនឹងទៅរើសយកតាំងពេលនៅងងឹត ឆាយនឹងរកមើល ៗ លុះគិតដូច្នោះហើយក៏ស្រដីទៅកាន់កុមារជ័យថា បើដូច្នេះចូរអាឯងនៅត្រង់ណោះចុះអញទៅមើលមួយភ្លែត បើកាលណាឮស្គរសំឡេងគងចូរអាឯងបើកទ្វារផង ៗ

កុមារជ័យ — សូមបងឯងដកគន្លឹះទុកឲ្យខ្ញុំឲ្យហើយទៅខ្ញុំដកមិនរួចទេ ក្រែងលោបងឯងទៅយូរខ្ញុំបើកមិនរួចនាំឲ្យហួសពេល ៗ អ្នកចាំទ្វារក៏ដកគន្លឹះទ្វារហើយដើរទៅ ៗ ខណៈនោះសំឡេងគងក៏លាន់ឮពេងឡើង ១ រំពេច ៗ

អ្នកចាំទ្វារ — អាត់តែរកមើលវត្ថុនៅទីកន្លែងដែលកុមារជ័យប្រាប់នោះ ឯកុមារជ័យទាញបង្អើបមាត់ទ្វារហើយកែះប្រាប់ទៅអាមាត្យនោះថានែ ! លោក ! បានឱកាសហើយ! ហ៊ឺ !... ភ្លែត ៗ

អាមាត្យក៏ខំស្ទុះចេញមកក្រៅដើរទៅកាន់ទីលំនៅរបស់ខ្លួននាព្រឹកនោះឯង ៗ

អ្នកចាំទ្វារលុះទៅរកមើលមិនឃើញក៏ត្រឡប់មកសួរកុមារជ័យវិញ កុមារជ័យក៏ធ្វើជាទៅរកជាមួយម្តងទៀត ៗ បានចាប់យកដុំគ្រួសមួយដុំដែលមានសម្បុរផ្លេកៗ បង្ហាញទៅអ្នកចាំទ្វារនោះថានែ ! លោកបងប្រហែលដុំនេះទេដឹងព្រោះខ្ញុំឃើញវានៅត្រង់ណឹង ៗ អ្នកចាំទ្វារក៏ទទួលយកដុំគ្រួសនោះពីដៃកុមារជ័យទៅ ហើយធ្វើភ្នែកក្លឹ ៗ មើលមុខកុមារ

ជ័យ ។

ការណ៍នេះបានរួចជ្រះស្រឡះហើយ កុមារជ័យនឹកត្រេកអរព្រួចក្នុងចិត្តលាន់មាត់តែម្នាក់ឯងថា មេ៉បអាឯងចង់ធ្វើបាបអញទៀត ឥឡូវស្រួលខ្លួនគ្រាន់បើទេ ។ ហើយដើរលោតកញ្ឆោតវ៉ាយកញ្ឆោងទៅប្រកបការតាមចំណាំរបស់ខ្លួន ។

X X X

កាលណោះពួកអស់អ្នកបានឃើញ កុមារជ័យលោតកញ្ឆោតវ៉ាយកញ្ឆោងយ៉ាងនោះ ក៏ទៅក្រាបបង្គំទូលព្រះមហាក្សត្រថា សូមទ្រង់ព្រះមេត្តាប្រោសអាជ័យវាលោតដាក់ទូលព្រះបង្គំសំបើមណាស់ព្រឹកមិញនេះ សូមទ្រង់មេត្តាប្រោសធ្វើទោសវា ទើបទូលបង្គំសុខចិត្ត ។

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលឲ្យហៅកុមារជ័យមកដល់ហើយទ្រង់សួរថា នែ! អាជ័យ! ហេតុអ្វីក៏អាឯងឡកដាក់អស់អ្នកដូច្នេះ ។

កុមារជ័យ – សូមទ្រង់មេត្តាប្រោស ឡកមែនតែមិនឡកដាក់អ្នកបងទាំងនោះទេ គឺឡកព្រោះតែមានសេចក្តីត្រេកអរចំពោះខ្លួនឯង ដែលបានបំពេញករណីយកិច្ចមួយយ៉ាងពិសេសផ្លែកពីធម្មតាក្នុងវេលាព្រឹកមិញនេះ ។

ព្រះមហាក្សត្រ – ចុះអាឯងបានធ្វើអ្វី នៅវេលាព្រឹកមិញនេះ បានជាអរដល់ទៅដាក់ឡកតែម្នាក់ឯងនេះ ។

កុមារជ័យ – សូមទ្រង់ព្រះមេត្តាប្រោស ព្រឹកមិញនេះទូលព្រះបង្គំបានទៅជួយមើលការបើកទ្វារព្រះបរមរាជវាំងជាមួយនឹងឆ្មាំទ្វារតាំងពីយប់ ការនោះក៏បានសម្រេចដូចបំណងនេះជាហេតុនាំឲ្យទូលព្រះបង្គំមានសេចក្តីត្រេកអរឥតឧបមាទៅដាក់ឡកតែម្នាក់ឯង ។

ព្រះមហាក្សត្រ បើដូច្នេះ! ចូរនាយទៅហៅអ្នកចាំទ្វារនោះមកអាយ អញនឹងសួរមើល តើការនេះពិតឬមិនពិតបើប្រសិនជាអាជ័យវាកុហកអញ ៗ នឹងយកទោស ។

អាមាត្យបានទៅហៅអ្នកចាំទ្វារនោះមកដល់ហើយព្រះមហាក្សត្រិយ៍ទ្រង់ត្រាស់សួរថា នែ! នាយ! ព្រឹកមិញនេះអាជ័យវាបានក្រាក់ពីយប់ទៅជួយបើកទ្វារឯងមែនឬទេ? ។

អាមាត្យ — បពិត្រមហារាជព្រឹកមិញនេះអាជ័យវាបានទៅជួយបើកទ្វារទូលព្រះបន្គំអ៊ីចឹងមែន ។

ព្រះមហាក្សត្រិយ៍ទ្រង់ព្រះដម្រិះថា អាជ័យនេះពេញទីជាក្មេងឧស្សាហ៍ជាក្មេងយកចិត្តទុកដាក់ធ្វើការបំរើព្រះមហាក្សត្រិយ៍ដោយហ្មត់ចត់អ៊ីចឹងមែន ។ បើយ៉ាងនេះត្រូវតែអញប្រោសប្រណីដល់វា ។ ប៉ុន្តែត្រូវប្រើឧបាយជាបណ្ដេញចេញពីព្រះបរមរាជវាំង កុំឲ្យពួកអស់អ្នកទាំងនោះកើតសេចក្ដីអាក់អន់ចិត្តនឹងអញ ថាសមដើងតែនឹងអាជ័យ ។

ក្រោយដែលព្រះអង្គបានទ្រង់ព្រះតម្រិះដូច្នេះហើយ ទ្រង់មានបន្ទូលទៅកាន់កុមារជ័យថា នែ! អាជ័យ! ត្រូវអាឯងចេញទៅពីវាំងអញទៅ មិនត្រូវអាឯងចូលមកកាន់វាំងទៀតទេ ព្រោះអាឯងប្រព្រឹត្តល្មើសធ្ងន់ណាស់ ។

(នៅមានត)

# បុណ្ណកុមារ

(តនឹងចប់)

## នឹកដល់រឿងដើម

បុណ្ណមាណពម្ភសត្យយុត្តរាជទូរស នៅក្នុងកល្យាណីបុរៈនគរមិនយូរប៉ុន្មានក៏នឹករលឹកដល់រឿងដើមរបស់ខ្លួនគឺនាងកុសលា ៗ សេចក្ដីស្នេហាដែលនៅជាប់ក្នុងបេះដូងមានអនុភាពយ៉ាងខ្លាំងក្លា ធ្វើឲ្យគេមិនអាចនឹងទ្រាំទ្រនៅក្នុងនគរបាន ទីបំផុតព្រះរាជកុមារក៏ខំប្រថុយចូលទៅសូមអនុញ្ញាតពីព្រះបិតាដើម្បីទៅលេងទេវគិរីនគរ ៗ ព្រះបាទសត្យរាជទ្រង់យល់ឃើញថា នឹងហាមឃាត់មិនបាន ព្រោះព្រះអង្គទ្រង់ជ្រាបច្បាស់នូវសេចក្ដីស្នេហា រវាងព្រះរាជបុត្រនឹងនាងកុសលាបុត្រី របស់មេទ័ពទសយុទ្ធក្នុងទេវគិរីនគរនោះ ព្រះអង្គក៏ទ្រង់អនុញ្ញាតឲ្យទៅ តែទ្រង់ប្រោសឲ្យសត្យទេវៈរាជអនុជយាងទៅជាមួយផង ព្រោះព្រះអង្គមិនជាទុកព្រះទ័យចំពោះរឿងនោះប៉ុន្មាន

“ឪពុកមិនសូវជាជឿថា គូរសង្សាររបស់កូនឯងនោះ នឹងនៅស្រឡាញ់-មានចិត្តត្រង់ចំពោះកូនឯងដែលមកក្លាយខ្លួនជាសត្រូវនៃស្រុកទេសគេដូច្នេះសោះ តែថាបើកូនចង់ទៅមើលឲ្យឃើញច្បាស់ដោយខ្លួនឯង មិនអីទេ ឪពុកក៏អនុញ្ញាតឲ្យទៅបាន តែថាត្រូវកូនឯងយកសត្យទេវៈប្អូនឯងទៅផង ដើម្បីប្រឹក្សា-ជួយគ្នាក្នុងគ្រាអាសន្នប្រសិនបើមានហេតុឡើង ឪពុកជឿជាក់ថារាជសីហ៍ពីរនៃកល្យាណីបុរៈនគរមុខជានឹងធ្វើការសម្រេចហើយបេមុខជានឹងនាំមកនូវជីវិត ព្រមទាំងដំណឹងល្អត្រឡប់មកវិញជាមិនខាន„ ៗ

ដូច្នោះ សត្យយុទ្ធានឹងសត្យាទេវៈ ក៏បានធ្វើដំណើរចេញពីកល្យាណីបុរៈនគរទៅមិនយូរថ្ងៃប៉ុន្មានក៏បានទៅដល់ទេវគិរីនគរ ។ ព្រះរាជកុមារទាំងពីរព្រះអង្គទ្រង់តែងកាយបន្ទំ ។ សត្យយុទ្ធាឬបុណ្ណមាណពទ្រង់ក្លែងក្លាយជាអ្នកជំនួញសំពត់បន្ទុកដោយរទេះមួយ ឯសត្យាទេវៈនោះក្លែងធ្វើជាកូនឈ្នួល ។

នៅថ្ងៃដំបូងដែលទើបនឹងទៅដល់ បុណ្ណមាណពបររទេះកាត់មុខផ្ទះនាងកុសលា ហើយចោលភ្នែកក្រឡេកមើលទៅឃើញនាងអង្គុយនៅមាត់បង្អួច មានមុខសៅហ្មងដោយការយំសោក បុណ្ណមាណពស្ទើរតែអត់ទ្រាំនឹងស្ទុះទៅឱបរិតលួងលោមនាងមិនបាន តែក៏បេះតែខំសង្កត់ចិត្តបររទេះបង្ហួសទៅ ។

លុះថ្ងៃទីពីរ ឈ្នួញសំពត់នេះក៏បររទេះមកត្រង់នេះទៀត ហើយពពាយនាយឃ្មើយ ៗ ពេលនោះដូចជានាងកុសលានៅមុខផ្ទះតែម្នាក់ឯងនាងឃើញដូច្នោះក៏ស្រែកហៅឈ្នួញឲ្យយកសំពត់ទៅមើលឈ្នួញនឹងឈ្នួលក៏កាន់សំពត់យកចូលទៅក្នុងផ្ទះដើម្បីឲ្យនាងរើសតាមត្រូវការ ។

ថ្ងៃនោះម្ដាយនាងមិននៅ ពួកអ្នកបម្រើក៏មិនដឹងជាទៅណាអស់បុណ្ណមាណពដែលស្ទាត់ជំនាញនូវផែនទីក្នុងផ្ទះស្រាប់បានឃើញដូច្នោះ ក៏ធ្វើជាងាកឆ្វេង-ស្ដាំ សត្យាទេវៈដឹងកលដូច្នោះក៏ធ្វើជាចេញទៅខាងក្រៅ ដើម្បីនឹងទៅជញ្ជូនយកសំពត់ពីរនេះដែលឈប់នៅមុខផ្ទះមកឲ្យនាងកុសលាមើលទៀត ។

ខណៈដែលនាងកំពុងតែជ្រើសរើសសំពត់នុ៎ះឯង បុណ្ណមាណពដែលតែងកាយបន្ទំនោះក៏ខ្សឹបប្រាប់នាងថា

«កុសលាអូនសម្លាញ់បង អូនចាំបងមិនបានទេឬ? បងគឺបុណ្ណមាណពរបស់អូនហ្នឹងឯង!»

នាងកុសលាភ្ញាក់ព្រើតហើយស្រឡាំងកាំងដូចរូបគ្មានវិញ្ញាណ ភ្នែកទាំងគូសម្លឹងមើលរង្វង់មុខរបស់អ្នកជំនួញសំពត់ស្តើងតែមិនប៉ព្រិច មួយសន្ទុះក្រោយមកទើប នាងចាំគេបាន ។ ទីបំផុតនាងក៏បានជួបនឹងបុណ្ណមាណពបុរសដែលនាងធ្លាប់ស្រឡាញ់រកអ្វីប្រៀបគ្មាន តែឥឡូវនេះសេចក្ដីស្នេហានោះបានក្លាយទៅជាសេចក្ដីព្យាបាទវិញហើយ ព្រោះនាងជឿតាមពាក្យរបស់វស្សុកៈថា បុណ្ណមាណពជាអ្នកសម្លាប់ឪពុករបស់នាងដោយប្រញ៉ៗ

បុណ្ណមាណពឃើញនាងក្រោកឈរឡើង ហើយញញឹមញញែមទាំងដែលមានទឹកមុខក្រៀមក្រំជាក់ខ្លួន បុណ្ណមាណពក៏ស្រវាចាប់ដៃស្ដាំនាងយ៉ាងថ្នម ៗ ពេលនោះគេក៏ឃើញនាងកុសលាបម្រះយ៉ាងខ្លាំងរបូតចេញពីគេទៅ ហើយដូចដឹងខ្លួនថា ឈឺផ្សា ៗ ត្រង់ពោះឃើញអ្វីសស្វាបនៅដៃរបស់នាង! ន៊ុគឺកំបិតស្នៀតដ៏មុតដែលចូលទៅក្នុងពោះអម្បាញ់មិញនេះ ភ្នែករបស់គេដ៏ស្រពាំងមើលអ្វីលែងឃើញទៀត គ្រាន់តែដឹងថា មាននរណាម្នាក់ស្ទុះចូលមក ហើយក៏លែងដឹងខ្លួនប្រាណទៅ....

បុណ្ណមាណពមកដឹងខ្លួនប្រាណ នៅពេលដែលបើកភ្នែកឡើងឃើញរង្វង់មុខរបស់សត្យាទរៈជាប្អូន កំពុងតែឈ្ងោកមើលមុខខ្លួនដោយសេចក្ដីព្រួយ

« បងសត្យយុត្តា! សូមសម្ងំនៅឲ្យស្ងៀម មិនអីទេ!» សត្យាទរៈពោលផងយកសំពត់ជ្រលក់ទឹកក្ដៅផ្ដិតលើថ្ងាសដ៏ក្ដៅអ៊ុនៗផង ។

« សត្យាទរៈ! បងទៅត្រង់ណាទឹងអូន?» បុណ្ណមាណពនិយាយដោយសំឡេងខ្សាវៗ ព្រោះឈឺខ្លួនទៅសព្វពាង្គកាយ

« នៅលើរទេះ យើងកំពុងតែធ្វើដំណើរត្រឡប់ទៅកល្យាណីបុរៈនគរវិញ»

« ចុះបងកើតអី? យី! ដូចជាត្រូវគេចាក់...»

« បងត្រូវគេចាក់មានរបួសជាទម្ងន់ » សត្យាទរៈពោល « នាងកុសលាសង្ក្រស ម្លាញ់បងជាអ្នកចាក់ ប្រសិនបើខ្ញុំចូលទៅយឺតតែបន្តិចប្រហែលជាស្រេចទៅហើយ ទុ ! បងអើយ ! នឹងយកអ្វីជាការទៀងទាត់ជាមួយស្រីបាន ! សូមបងសម្ងំដេកទៅ ! »

បុណ្ណមាណពនឹកចង់ស្តរសោកអ្វីៗតទៅទៀត តែដូចជាអស់កម្លាំងទន់ខ្លួនប្រាណ ទៅអស់ ទើបធ្មេចភ្នែកដេកលក់ទៅវិញយ៉ាងល្ងឹងល្ងើយ ។

សត្យាទរៈបញ្ឈប់រទេះជារយៈៗ ព្រោះក្រែងថាការរលាក់នៃរទេះនឹងធ្វើឲ្យមុខដំ- ណៅបេះតែហូរឈាមចេញមកទៀត ។ គេរុំរក្សាមុខដំណៅនោះដោយម៉ត់ចត់ ក្នុងពេល ៧ ថ្ងៃដំបូង បុណ្ណមាណពបេះតែមមើមមាយដោយពុទ្ធគ្រុន ដែលបណ្តាលមកពីមុខ- របួស សត្យាទរៈគិតថា បើនឹងធ្វើដំណើរយឺតយូរយ៉ាងនេះ ក្រែងមានទាហាននៃទេវ គិរីនគរដេញតាមមក តែក៏គួរថ្លុកណាស់ដែរ ព្រោះតាំងពីពេលបររទេះចេញមកពីទ្វារនគរ ក៏ដូចជាគ្មានឃើញពួកទាហានដេញតាមមកសោះ ។

ស្នាមរបួសនោះ ដូចជាគ្រោះល្អគ្រាន់បើ ព្រោះមិនជាប់ពោះវៀនឬថ្លើមក្រពះ តែបើទុកណាជាដូច្នោះ ក៏មានអន្តរាយមិនតិច បុណ្ណមាណពដេកសន្លប់សន្លំនលែងដឹង ខ្លួនប្រាណ ៣ យប់ ៣ ថ្ងៃ ។

ក្នុងទីបំផុត ក្រោយពីការឈប់សម្រាកខ្លះក្នុងការធ្វើដំណើរជាង ៣ អាទិត្យមកដោយ ត្រូវឈប់ព្យាបាលរបួសនោះច្រើនលើកច្រើនគ្នា សត្យាទរៈក៏បាននាំបុណ្ណមាណព ជាបងមកដល់កល្យាណីបុរៈនគរបាន ហើយបុណ្ណមាណពក៏បានធូរស្បើយបន្តិចឡើង ដែរ ។

ព្រះបាទសត្យរាជ ទ្រង់ព្រះរាជតក្កក្នុងអាការភេតរបស់សត្យយុត្តា រាជបុត្រសយ៉ាងខ្លាំង

ព្រះអង្គទ្រង់ត្រាស់បង្គាប់ឲ្យគ្រូពេទ្យប្រចាំរាជវាំងចាត់ការរក្សាយ៉ាងម៉ត់ចត់ មិនយូរប៉ុន្មាន សត្យយុទ្ធាក៏បានជាសះស្បើយទៅ ។

សត្យាទរៈបានបរិយាយឲ្យគេស្តាប់ថា ខណៈដែលនាងកុសលាចាកគេនោះសត្យាទរៈនៅមិនទាន់បានចុះចេញផុតពីផ្ទះនៅឡើយទេ ព្រោះបេះតែគិតថា ក្រែងមានហេតុកើតឡើង គេបានលបចាំមើលលុះមានរឿងក្តាម គេក៏ស្ទុះចូលទៅក្តាមវិញដែរ តែស្ទុះចូលទៅមិនទាន់នាងកុសលាគ្រាន់តែឃើញគេស្ទុះចូលទៅ ក៏គេចចូលទៅក្នុងផ្ទះបាត់ទៅ គេក៏ប្រញាប់ប្រញាល់គ្រាហ៍យកខ្លួនដែលប្រាសចាកស្មារតីរបស់បងចេញពីផ្ទះទៅបានហើយ នាំយកទៅដាក់លើរទេះដែលឈប់នៅមុខផ្ទះ ប្រញាប់បរចេញទៅក្តាមទៅ...

បុណ្ណមាណពអង្គុយស្តាប់ប្អូននិយាយដោយចិត្តប្រកបដោយទោសៈ សព្វាង្គកាយទាំងអស់ញ័រដោយកំហឹង

«ចាំបងជាមែនទែនសិន» សត្យាទរៈពោល «យើងនឹងលើកកងទ័ពទៅវាយទេវគិរីនគរ ដើម្បីសងនឹងការរុករាន នឹងដើម្បីសងកំហឹងនៃការកាឡកណ្ណីរបស់នាងកុសលា នារីចិត្តខ្មៅនោះឲ្យទាល់តែបាន...»

បុណ្ណមាណពនៅស្ងៀមមិនឆ្លើយថាអ្វី បើទុកជាមានការឈឺចិត្តយ៉ាងខ្លាំងនឹងនារីដែលខ្លួនបានប្រតិព័ទ្ធស្នេហានោះក៏ដោយ បុណ្ណមាណពបេះតែគិតថា ទេវគិរីជានគរដែលធ្លាប់មានគុណឧបការៈលើខ្លួន ជានគររបស់លោកមេទ័ពទសយុទ្ធឪពុកចិញ្ចឹមរបស់ខ្លួនដែលឥឡូវស្លាប់ទៅហើយ ៗ ដែលធ្លាប់ស្រឡាញ់ខ្លួនរកអ្វីប្រៀបគ្មាន បានថ្នាក់ថ្នមថែទាំទំនុកបម្រុងខ្លួនតាំងពីតូចៗ ទាល់តែខ្លួនបានធំទាំងរូបនឹងមានចំពោះវិជ្ជា បានធំទាំងយសសក្តិផង ការដែលនឹងលើកទ័ពទៅវាយទេវគិរីនគរនោះ បុណ្ណមាណពមិនអាចនឹងធ្វើកើត ព្រោះខ្លួនជាមនុស្សមានកតញ្ញូកតវេទីចំពោះបុគ្គលដែលមានគុណឧបការៈលើខ្លួនៗ

## លោកនេះមានអ្វីទៀងទាត់–មានអ្វីជាសន្តិសុខ?

សភាពជាព្រះរាជឱរស, ជាព្រះរាជទាយាទនៃបុណ្ណមាណព ក៏មិនបានធ្វើឲ្យបុណ្ណមាណពសប្បាយរីករាយទៅកើតឡើយ ព្រោះលោកគ្មានអ្វីទៀងទាត់–គ្មានជាសន្តិសុខ!

បុណ្ណមាណពនេះតែងគិតដល់រឿងនេះជានិច្ច ៗ គេធ្លាប់បានទៅមើលការបង្ហាត់បង្រៀនពួកទាហាននៃកល្យាណីបុរៈនគរ ហើយចេះនឹកសង្វេគក្នុងចិត្តជានិច្ចថា ឱ! ពួកទាហានអ្នកស្រុកឃ្មានទូវសង្គ្រាមអើយ នៅពេលឆាប់ៗ នេះ ពួកអ្នកទាំងឡាយនឹងនាំគ្នាទៅជាន់ដែនដីទេវគិរីនគរ ពួកអ្នកទាំងឡាយនឹងបានទទួលនូវបរាជ័យ ឬអបរាជ័យ ក៏ស្រេចហើយតែហេតុការណ៍ខាងមុខ តែការពិតដែលមិនអាចនឹងចៀសវាងបាននោះគឺ ក្នុងបណ្ដាពួកអ្នកទាំងឡាយនេះ នឹងមានគ្នាប៉ុន្មាននាក់ដែលអាចរួចរស់ជីវិតត្រឡប់មកជួបមុខនឹងប្រពន្ធកូនម៉ែឪបងប្អូន ដែលរង់ចាំតែខ្លួននៅឯផ្ទះនោះ?...

បុណ្ណមាណពគិតដល់រឿងនេះក៏រឹងរឹតតែសង្វេគក្នុងចិត្តណាស់ទៅទៀតថា ឱ! សង្គ្រាម! សង្គ្រាមជាធម្មជាតិកំណាចណាស់ទេតើ សង្គ្រាមធ្វើឲ្យបុរសៗស្លាប់ សង្គ្រាមធ្វើឲ្យស្ត្រីៗ មេម៉ាយ សង្គ្រាមធ្វើឲ្យក្មេងៗ កំព្រាគ្មានម៉ែឪគ្មានទីពឹង សង្គ្រាមធ្វើឲ្យកូនព្រាត់ម៉ែឪ ធ្វើឲ្យម៉ែឪព្រាត់ប្រាសកូន ឱ! សង្គ្រាម! សង្គ្រាមធ្វើឲ្យក្ដៅ ធ្វើឲ្យក្ដៅក្រហាយគ្រប់ទិសទីទូទៅលើដែនដី! ឱ! សង្គ្រាម! សង្គ្រាមកំណាចណាស់ហ្ន៎! ឱ! លោកនេះអើយ! ម៉េចក៏មានកម្មពៀរអីច្រើនម្ល៉េះហ្ន៎!!!...

ក្នុងទីបំផុត បុណ្ណមាណព ឬសត្យយុទ្ធព្រះរាជឱរសរបស់ព្រះបាទសត្យរាជ រាជានៃកល្យាណីបុរៈនគរ ក៏ទ្រង់យល់ឃើញច្បាស់ថា ក្នុងលោកនេះគ្មានអ្វីទៀងទាត់! សូម្បីតែនារីជាទីស្នេហារបស់អាត្មាអញ ដែលគួរតែទុកចិត្តមានទៀងទាត់មិនប្រែប្រួល

ផ្កាស់ប្តូរ ក៏មិនទៀងទាត់មានចិត្តប្រែប្រួលផ្លាស់ប្តូរទៅដែរ ក្នុងលោកនេះគ្មានសន្តិសុខ! សូម្បីបើទុកជាមានពុកទាហានសម្រាប់ការពារនូវសន្តិសុខនោះ ទីបំផុតក៏នាំគ្នាទៅធ្វើសង្គ្រាមប្រាំងកាប់សម្លាប់គ្នាលេងទៅវិញ! ការរស់នៅបែបផ្សេងៗក្នុងលោក រមែងបង្កឲ្យកើតនូវសេចក្តីសៅហ្មងនិងសេចក្តីក្តៅក្រហាយជាទុក្ខយ៉ាងខ្លាំង!

រាត្រីមួយ ដែលប្រកបដោយរស្មីនៃព្រះចន្ទបែងចាំងភ្លឺត្រចះស្រទន់ត្រជាក់ ហាក់ដូចជារាត្រីដែលនាំមកនូវសេចក្តីសុខចំពោះមនុស្សភាគតិច ដែលយល់ច្បាស់នូវត្រៃលក្ខណ៍ តែថាហាក់ដូចជារាត្រីដែលនាំមកមហាទុក្ខចំពោះមនុស្សភាគច្រើនដែលមិនបានពិចារណានូវសភាពបែបនោះ...ៗ

បុណ្ណមាណពដាច់ចិត្តស្រែកណាព្រះរាជវាំង ទីដ៏សែនសុខនាលោកិយនៃកល្យាណីបុរៈនគរចេញទៅទាំងរាត្រីដោយមានឧត្តមគតិតែម្យ៉ាងថា នឹងស្វែងរកសន្តិសុខ...

ព្រះបាទសត្យរាជក៏ទ្រង់បាត់ព្រះរាជឱរសច្បងម្តងទៀតហើយ ដោយគ្មានលេចឮដំណឹងថា ទៅនៅទិសទីតំបន់ណាសោះឡើយ ក្រៅពីចុតហ្មាយមួយច្បាប់ដែលព្រះរាជឱរសប្អូនទុកចោលនៅរាជតំណាក់ប៉ុណ្ណោះ ដែលសូមអង្វរឲ្យព្រះអង្គឈប់លែងគិតលើកទ័ពទៅធ្វើសង្គ្រាមនឹងទេវគិរីនគរទៀត ដើម្បីសេចក្តីសន្តិសុខរបស់អាណាប្រជានុរាស្ត្រទាំងពីរនគរតទៅ...ៗ

ព្រះបាទសត្យរាជទ្រង់គោរពព្រះទ័យយ៉ាងខ្លាំង ទ្រង់ក៏ត្រាស់បញ្ជាឲ្យបញ្ឈប់ការលើកទ័ពទៅវាយទេវគិរីនគរភ្លាម ឯសត្យាទេវៈ ក៏ទ្រង់មានសេចក្តីអាឡោះអាល័យចំពោះព្រះរៀមបងខ្លាំងណាស់ដែរ ទីបំផុតធ្វើដំណើរចេញទៅស្វែងរកព្រះរៀមបងគ្រប់ទិសទី តែក៏មិនបានរកឃើញ សូម្បីត្រឹមតែដំណឹងលេចឮក៏គ្មានទៀត...

ដូច្នោះ កល្យាណីបុរៈនឹងទេវគិរីនគរក៏លែងធ្វើសឹកសង្គ្រាមនឹងគ្នា ហើយតមកមិន

យូរប៉ុន្មាន នគរទាំងពីរក៏បានបញ្ជូនរាជទូតមកចរចាគ្នា នឹងចងសម្ពន្ធមេត្រីរវាងគ្នានឹងគ្នាថា នឹងគោរពសន្តិភាពនឹងអធិបតេយ្យភាពគ្នាទៅវិញទៅមក ... ព្រោះសង្គ្រាមដែលទើបនឹងកន្លងទៅថ្មីៗ នេះ ជាកស្តុតាងមួយបង្ហាញឲ្យឃើញថា ការច្បាំងកាំងដល់កាប់សម្លាប់គ្នានឹងគ្នា មិនមែនជាការនាំមកនូវសន្តិសុខឲ្យដល់ប្រជាជនសូម្បីតែបន្តិចបន្តួចសោះឡើយ ...។

ចាប់តាំងពីនោះមក កល្យាណីបុរៈនឹងទេវគិរីនគរ ក៏ក្លាយទៅជានគរដែលមានតែសន្តិសុខ អាណាប្រជានុរាស្ត្រក៏បានប្រកបការចិញ្ចឹមដោយសេចក្តីត្រជាក់ត្រជុំស្រណុកសុខសប្បាយប្រាសចាកភយន្តរាយ សប្បាយរីករាយអស់កាលជាយូរ ...។

ក្នុងវត្តតូចមួយនៅដែនបេតវ័ត៌ ដែលតាំងនៅខាងលើមាត់ស្ទឹងគោទាវរីឆ្ងាយចេញទៅទិសពាយព្យនៃទេវគិរីនគរ ភិក្ខុពង់ទ្រនាប់មានបែបភាពសង្រឹមមួយអង្គកំពុងអង្គុយធ្វើសមាធិយ៉ាងស្ងប់ស្ងៀមនៅក្រោមម្លប់ឈើមួយដើម ដែលមានវល្លិ៍ព័ទ្ធព័ន្ធស៊ុំទ្រុំក្បែរមាត់ទឹក លោកគង់សង្រឹមស្ងៀមយ៉ាងស្រគត់ស្រគំ មានព្រះទ័យសប្បាយក្នុងសមាធិនោះ ទាល់តែមិនបានជាសង្កេតថា នៅខាងក្រោយលោកមិនជាឆ្ងាយប៉ុន្មានប្រហែលជា ៤ ព្យាមប៉ុណ្ណោះ មានយាយជីក្រមុំម្នាក់ដើរតាមក្រោយយាយជីចាស់ម្នាក់ទៀតចូលមក ហើយយាយជីចាស់នោះខ្សឹបប្រាប់យាយជីក្រមុំខ្សាវៗ ថា

«នុះហ្ន៎! លោកគ្រូបុណ្ណៈ ភិក្ខុដែលពួកយើងគ្រប់គ្នាតែងគោរពបូជា លោកមានព្រះទ័យល្អ ប្រព្រឹត្តតែងតែកាន់ពុទ្ធសាសនាជាតួយ៉ាងរបស់ភិក្ខុ-សាមណេរទាំងឡាយក្នុងវត្តនេះ...»

យាយជីក្រមុំនោះធ្វើក្អែកក្អួសៗ ព្រមទាំងខ្សឹបខ្សាវៗ ឆ្លើយទៅវិញថា

«លោកកំពុងតែគង់ធ្វើសមាធិ កុំអាលរំខានលោកធ្វើអី!»

ខណៈនោះ ភិក្ខុអង្គនោះក៏បែរព្រះភក្ត្រទៅរកយាយជីទាំងពីរនាក់ លុះឃើញយាយជីគ្រុមុំ ក៏ដូចជាស្រទន់ទៅមួយសន្ទុះ តែក៏ចំប្រមូលអារម្មណ៍មកវិញ ហើយក៏សួរទៅដោយសម្លេងប្រក្រតីថា

"មានធុរៈអី! ញោម?"

ពេលនោះយាយជីគ្រុមុំក៏ស្ទុះចូលទៅជិត នាំងបន្ទាបខ្លួនចុះស្ទើរតែនឹងប៉ះព្រះបាទរបស់ព្រះភិក្ខុរូបនោះ ដៃទាំងពីរប្រណម្យក្រាបចុះថ្វាយបង្គំដោយគោរព ហើយក៏យំសោកខ្សឹកខ្សួលនៅចំពោះព្រះភក្ត្ររបស់ភិក្ខុរូបនោះ ដែលតាមការពិតនាងខំអត់សង្កត់ស្ទើរស្លាប់មិនចង់ឲ្យទឹកភ្នែកហូរធ្លាក់ចុះមក តែវាហួសវិស័យនឹងអត់បាន ព្រោះពេលនោះដូចជាមានអ្វីមួយបាញ់បញ្ចេញទឹកភ្នែកនាងឲ្យហូរចុះមក ៗ

"ម៉េចអញ្ចឹងញោម!" ព្រះភិក្ខុរូបនោះពោលឡើងព្រមទាំងអង្គុយញញើតដើងចូលលោកព្យាយាមក្លើសិងដឹងឲ្យចេញមកជាប្រក្រតីតែវានៅតែញ័រៗ តិចៗ

"ខ្ញុំព្រះករុណាមកសូមអភ័យទោស!" យាយជីគ្រុមុំនិយាយផងយំផង "ខ្ញុំព្រះករុណាជាមនុស្សអាក្រក់សាមាន្យ ព្រោះខ្ញុំព្រះករុណាយល់ខុស ហើយបានបង្កកម្មអាក្រក់ដងចំពោះព្រះតេជគុណ សូម្បីខ្ញុំព្រះករុណាស្បៀកពាក់សគោសក់កាន់សមណៈភេទតីបួសជាយាយជីដូច្នេះទៅហើយក៏ដោយ ក៏នៅតែព្រួយបារម្ភជានិច្ចថា នៅមិនទាន់បានទទួលនូវការអភ័យទោសអំពីសំណាក់ព្រះតេជគុណ ..."

"គ្មានអ្វីនៅសល់ជាទោសពៃរទេញោម!" ព្រះភិក្ខុពោល "អាត្មាអភ័យទោសឲ្យយូរណាស់ទៅហើយ ការចងពៀរជាបាប!... បង្កការមិនឲ្យកើតឡើងដល់ចិត្ត!..."

ពុទ្ធដីការរបស់ភិក្ខុនោះដាច់តែត្រឹមនោះ ព្រោះយាយជីគ្រុមុំចេះតែយំខ្សឹកខ្សួលខ្លាំងឡើង ៗ

« ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំព្រះគុណរបស់ព្រះតេជគុណ ហើយនឹងនឹករលឹកចំពោះព្រះគុណដ៏ធ្ងន់នេះរហូតដល់ថ្ងៃស្លាប់ ហើយនឹងសូមប្តេជ្ញាថា នឹងស្លាប់ក្នុងភេទនេះ »

« ល្អណាស់ហើយញោមអើយ ! » ព្រះភិក្ខុពោល « ក្នុងលោកនេះគ្មានអ្វីនឹងឲ្យសេចក្តីសុខដល់មនុស្សបានដូចព្រះធម៌នៃសមណទ្រឡើយ ព្រោះពុទ្ធធម៌គ្មានការស្អប់ខ្ពើម គ្មានអាឃាតព្យាបាទ គ្មានរឿងនាំឲ្យសៅហ្មង ល្អណាស់ហើយដែលញោមតាំងចិត្តថានឹងបួសដល់ស្លាប់នោះ ព្រោះអាត្មាក៏តាំងចិត្តដូច្នោះដែរ... »

សម្លេងរគាំងបានលាន់ឮល្វើយៗ មកពីក្នុងវត្ត ព្រះភិក្ខុបុណ្ណៈក៏ក្រោកឈរឡើង យាយជីចាស់ដែលមិនបានដឹងរឿងរ៉ាវអ្វីសោះ ចំពោះពាក្យសំដីនៃព្រះភិក្ខុបុណ្ណៈនឹងយាយជីក្មេងក៏តៀនថា ៗ

« ទៅ ! យើងត្រឡប់ទៅវិញយាយជីកុសលា ដល់ពេលលោកទៅនមស្ការសូត្រធម៌នៅក្នុងព្រះវិហារហើយ... »

យាយជីកុសលាក្រាបថ្វាយបង្គំព្រះភិក្ខុបុណ្ណៈម្តងទៀត... ថ្ពាល់ទាំងពីរជោគជាំដោយទឹកភ្នែក... ។

ព្រះភិក្ខុបុណ្ណៈ និមន្តតម្រង់ទៅព្រះវិហារដោយការសង្រួមយ៉ាងស្រគត់ស្រគំ ព្រះនេត្រទាំងពីរសម្ដៅទៅខាងមុខប្រហែលមួយដូរនឹមប៉ុណ្ណោះ លោកមិនងាកទៅមើលយាយជីទាំងពីរនាក់ដែលកំពុងតែនាំគ្នាដើរសំដៅទៅកាន់ខ្ទមសំណាក់ ដែលមើលទៅឃើញលឹមៗ នៅឯមុខនោះឡើយ ។

ប់ប់

រោងពុម្ពទិវិយ
នៅខាងត្បូងផ្សារអូរឫស្សីសង្កាត់លេខ៥